ទស្សនាវដ្ដី លេខ ១១



Don Offert par M.
IMPRIMERIE VIRIYA P.PENH

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | វិចារណកថា | ទំព័រទី | ១ |
| | ដំណើរសាសនា | " | ៣ |
| ភិក្ខុ អាំ-សួន (ហៅ ហម) | សាសនាជេន និងពុទ្ធសាសនា | " | ៩ |
| ភិក្ខុ លី-គឹមឡុង | ពិធីបុណ្យឆ្លងឆដ្ឋសង្គាយនា | " | ១៤ |
| ព្រះពុទ្ធវង្ស កៅ-ស៊ឹម | បុព្វការិនិវេសន៍ | " | ១៨ |
| ព្រះគ្រូបវរតិម្ពលី អ៊ូ-ចេវ | ធនញ្ជយបណ្ឌិត | " | ២២ |
| លោក កែ-ជុន | ជ័យព្រាជ (ត) | " | ២៥ |
| ភិក្ខុ អាំ-សួន (ហៅ ហម) | វេទនាវិលាសវាក្យការសាអន់គ្រូស | " | ៣៨ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលជាវ


សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ស្មៀនការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# សេចក្ដីជូនដំណឹង

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ ដែលបានជាវទស្សនាវដ្ដីនេះ ហើយពុំទាន់បានបង់តម្លៃជាវនៅឡើយនោះ សូមទានមេត្តាផ្ញើបច្ច័យ ប្រាក់ទៅបង់តម្លៃឲ្យទានដោយអនុគ្គហភាព ៗ ព្រោះពលភាពនៃថវិកាសម្រាប់បំណាយបោះពុម្ពនោះ កាន់តែខ្សត់ខ្សោយណាស់ទៅហើយ ៗ

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ មេត្តាជួយឧបត្ថម្ភទំនុកបំរុងជីវភាពនៃទស្សនាវដ្ដីនេះឲ្យមានពលភាព-វឌ្ឍនភាពជាស្ថាពរតទៅឲ្យទានផង។ ៗ

សូមអរគុណទុកជាមុនដ៏ជ្រាលជ្រៅដោយសេចក្ដីស្មោះស្ម័គ្រ។ ៗ

# វិចារណកថា

## ជីវិត សង្គម សន្តិភាព

យើងបានដឹងរួចមកហើយថា ពិភពលោកកំពុងតែចោទបញ្ហាទាំងបីនេះលើផ្នត់គំនិតនៃអ្នកនយោបាយទូទៅ ហើយគ្រប់ប្រទេសនានាដែលមាននៅលើដុំចក្រវាឡនេះ។ តែយើងមិនទាន់ច្បាស់ថា តើបញ្ហាទាំងបីនេះត្រូវចោទទៅតាមផ្លូវណាទៅវិញ? ហើយសំខាន់បំផុតលើគោលការណ៍អន្តរជាតិគេបានយកចិត្តទុកដាក់យ៉ាងក្រៃលែង ដើម្បីដោះស្រាយ ប៉ុន្តែគេមិនដែលពោលដល់ច្បាប់គោលដែលជាបាទនៃបញ្ហាទាំងនោះទេ!

ខ្ញុំសូមជំរាបដល់អ្នកប្រាជ្ញវិទ្យាសាស្ត្រពិភពលោកថា ការដោះស្រាយបញ្ហាលោក បើនៅតែដំណើរតាមវិធានការសើៗដូចមានមកសព្វថ្ងៃនេះ សង្គមសាសនាទាំងមូលអាចចោទបំថា នឹងដោះស្រាយមិនបានជាដាច់ខាត ព្រោះដោយពិតៗមែនៗសព្វថ្ងៃគេពេញចិត្តយកលទ្ធិមកដោះស្រាយលើបញ្ហាពិភពលោក ដែលកំពុងតែមានមកលើស្ថានការណ៍អន្តរជាតិ ។

ខ្ញុំគ្រាន់តែជំរាបថា តើគោលការណ៍ទាំងបីនេះមានន័យប្រាកដបែបណាទៅវិញ?

ជីវិត– យើងធ្លាប់ដឹងថា ជានាមធម៌សម្រាប់ទ្រទ្រង់ខាងអ្វីដែលមានពណ៌ ប្រកបដោយវិញ្ញាណ មានសភាពចាញ់ធម្មជាតិជាធម្មតា ។

សង្គម– ការរួមនៃជីវិតទាំងអស់ដែលអាស្រ័យនៅប្រជុំប្រសងជាមួយគ្នា ។

សន្តិភាព– រួមសង្គមទាំងអស់ដែលប្រាសចាកការវង្វេងយោបល់នឹងយល់ទាស់

មានអន្តរាយកើតឡើងដោយអាឃាតព្យាបាទ ឬបង្កឡើងដោយធម្មជាតិឡើយ ។ ន័យនៃពាក្យសន្តិភាពអ្នកប្រាជ្ញលោកបានចែកចេញជាពីរប្រភេទផ្សេងគ្នា គឺសន្តិភាពជាលោកិយ និងជាលោកុត្តរៈ ។ ការរំងាប់បណ្ដាញខាងក្រៅហៅថាសន្តិភាពលោកិយ ការរំងាប់បណ្ដាញខាងក្នុងហៅថាសន្តិភាពលោកុត្តរៈ ។

យើងសូមពោលឲ្យចំតែម្ដងថា ទីណាក៏ដោយដែលនៅលើផែនដីនេះ ក៏សុទ្ធតែមានជីវិតទាំងអស់ ហើយបណ្ដាជីវិតទាំងនោះគេតែងខ្វាបរឯងដល់សភាពវិនាសទៅវិញជាធម្មតា តែទោះម្ដេចបើជីវិតជាសភាពកសាង ក៏ត្រូវតែមានសភាពវិនាសទៅវិញជានិច្ច ហើយកម្លាំងជីវិតនេះ នឹងនាំលោកទាំងមូលបង្កឡើងបានជាសង្គមតូចធំសម្រាប់ប្រឆាំងធម្មជាតិ ព្រោះធម្មជាតិជាដំណើរអយុត្តិធម៌មួយរបស់ជីវិតនៃអ្នកតស៊ូទាំងឃើញទាំងពុំឃើញ ។ សម័យនេះគេកំពុងធ្វើអ្វី ដើម្បីប្រឆាំងនឹងធម្មជាតិ ; គេក៏អាចឆ្លើយភ្លាមថា សាងសន្តិភាព ។ តើអ្នកណាជាអ្នកសាងសន្តិភាព? ជាមនុស្សជាអ្នកសាង ! ហើយមនុស្សនោះនៅទីណា ? ជានៅក្នុងសង្គមលើដុំលោកនេះ តែបើសង្គមមនុស្សប្រឹងសាងសន្តិភាពជាមួយនឹងអំពើលោភ នោះពេលណាហ្ន៎ដែលគេអាចជួបប្រទះពន្លឺសន្តិភាពបាន? គេហ៊ានចោទចំថាសង្គមណាក៏ដោយ ដែលតាំងខ្លួនថាជាអ្នករក្ស នឹងស្វែងរកសន្តិភាព ក៏សុទ្ធតែស្វែងរកតាមបន្ទាយនៃអំពើលោភទាំងអស់ ។

បើយ៉ាងនេះ លើមាគ៌ានយោបាយសម្រាប់សន្តិភាព ក៏ឃើញថាពុំទាន់រកដំណៅទៀច្បាស់ដើម្បីរក្សាសន្តិភាពលោកបានឡើយ ហើយម្នាក់ៗ នៅតែបបួលគ្នាបណ្ដើតខ្លួនទៅតាមបំហាយ ឬ ខ្យល់នៃនយោបាយសន្តិភាពលោកនៃប្រទេសជាមេលទ្ធិប៉ុណ្ណោះ ។

ខ្ញុំសូមអំពាវនាវឲ្យអ្នកប្រាជ្ញវិទ្យាសាស្ត្រ និងអ្នកនយោបាយសន្តិភាពផ្លាស់មធ្យោបាយតាមសន្តិភាពសាសនាវិញ ។ បណ្ណាធិការ

# ដំណឹងសាសនា

(តនឹងបប់)

លុះរួចពល់កិច្ចបួងសួងហើយ, គ្រហស្ថទាំងឡាយក៏លើករណ្ដាប់ទេយ្យទានប្រគេនព្រះមហាថេរគ្រប់ទាំង១០អង្គ ។ កាលទទួលទេយ្យទានរួចស្រេចបាច់, ក៏បានថ្វាយបង្គំលាសម្ដេច ចេញមកតង់សម្រាកខាងក្រៅនាកន្លែងសមគួរ អស់កាលយូរបន្តិច ទើបនិមន្តទៅអាពាមវិញ នៅតែសម្ដេចព្រះសុមេធាធិបតី ព្រោះត្រូវការប្រទានធម្មទេសនាក្នុងរាត្រីនោះ ។

ម៉ោង ២១, ២៥ បាននិមន្តព្រះសង្ឃ ៧៨ អង្គចំរើនព្រះបរិត្តដោយសង្ខេបនៅក្នុងព្រះវិហារ ហើយនិមន្តសម្ដេចព្រះមហាសុមេធាធិបតីប្រទានធម្មទេសនាតាមប្រពៃណី ។ សម្ដេចបានលើកយកព្រះពុទ្ធភាសិតមកសម្ដែងជាគាថថា

បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ
សច្ចេន កិត្តិំ បប្បោតិ ទទំ មិត្តានិ គន្ថតិ ។

តម្រូវទៅតាមសុន្ទរកថា លោកសាស្ត្រាចារ្យ ឈឹម-ស៊ុម ដែលថ្លែងជាតំណាងសិស្សទាំងបញ្ជិតទាំងគ្រហស្ថនៅលើធម្មាសន៍ ។

ព្រះធម្មទេសនារបស់សម្ដេច មានអត្ថរសដ៏ផ្អែមល្ហែមគួរឲ្យចាប់ចិត្តជាពន់ពេក ព្រោះសម្ដេចមានបដិភាណដ៏បរិបូណ៌ខាងអត្ថវោហារ ។

មុននឹងបញ្ចប់, សម្ដេចបានបួងសួង សូមឲ្យអានុភាពនៃព្រះធម៌ទេសនា ដែលបានសម្ដែងដោយព្រះទ័យដ៏បរិសុទ្ធ ដោយមិនប្រាថ្នាលាភសក្ការៈ ឬបៀតបៀនអ្នកណាមួយ

នោះ ជួយអភិបាលរក្សាសម្តេចព្រះធម្មលិខិតឲ្យសះស្បើយចាកព្រះរោគ នឹងសូមឲ្យតេជៈនៃធម៌នោះ ជួយបង្ហាញនូវឱសថដ៏ចំណាន ដល់គ្រូពេទ្យដែលកំពុងតែព្យាបាលសព្វថ្ងៃ ដើម្បីឲ្យព្យាបាលឆាប់រហ័សសះស្បើយក្នុងពេលដ៏ខ្លីខាងមុខនេះ ។ ព្រះធម្មទេសនានេះចប់នៅម៉ោង២៣ ។ សម្តេចបានគង់សម្រាកក្នុងព្រះវិហារ ពោលរៀបរាប់ពីព្រឹត្តិការណ៍ពុទ្ធសាសនាក្នុងប្រទេសសាកលលោក មានសហភាពភូមាជាដើម ជាមួយព្រះសង្ឃដែលគង់គាល់ក្នុងទីនោះ ដរាបដល់ម៉ោង ២៤, ៤០ ទើបនិមន្តទៅវត្តលិនៅវិញ ។

រាត្រីសោរពារមានឫក្សល្អ បានកន្លងផុតទៅដោយគតិជាសុភមង្គលដ៏ប្រសើរចំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ព្រោះជាកាលបរិច្ចេទតិចដែលពុទ្ធសាសនិកទាំងបព្វជិតទាំងគ្រហស្ថ បានរួបរួមគ្នាធ្វើបុណ្យកតញ្ញូ ប្រកបដោយគារវភក្តិភាព នឹងមនោសញ្ចេតនាដ៏បរិសុទ្ធ ចំពោះឧបការគុណដ៏ធ្ងន់ ទាំងជារាត្រីប្រកបដោយសព្ទសាធុការពរ នឹងការបួងសួងគុណធម៌ ឲ្យជួយបន្សាបឥទ្ធិពលរោគ ដែលបញ្ចេញអំណាចដ៏ឃោរឃៅកំឡៅហួសហេតុ ជ្រែកចូលមកបៀតបៀនព្រះអង្គកាយសម្តេច ឲ្យវិនាសបាត់បង់ទៅ នឹងសូមឲ្យមានព្រះកាយពលរឹងប៉ឹងជាភិយ្យោភាពផង ។

## ថ្ងៃទី ២ នៃកាលបរិច្ចេទបុណ្យ

ថ្ងៃអាទិត្យ ទី ១០ ខែ ឆ្នាំដដែល, ពេលព្រះអរុណោទ័យមានរស្មីដ៏ស្រទន់ រះផុតបុងព្រឹក្សានានា, គណៈកម្មការទាំងឡាយ បានរៀបចំកន្ទេលដាក់បាត្រប្រគេនព្រះភិក្ខុសាមណេរ ដែលគេបាននិមន្តមកពីវត្តមហាមន្ត្រី ៣០ រូប វត្តកោះ៣០ រូប វត្តបទុមវតី ១៨ រូប រួមជា៧៨រូប នៅខាងជើងហោត្រ័យនឹងធម្មកុដិ, ជាពិសេស គេ

បានរៀបកន្ទេលមួយនៅឰធម្មកុដិ សម្រាប់សម្ដេចដាក់បាត្រដៃរ ៗ គ្រហស្ថទាំងឡាយចេះតែមកតាមលំដាប់ មុនពេលដែលបានកំណត់ក្នុងកម្មវិធីបុណ្យ ដែលយើងបានឃើញជាអាទិ គឺលោក រ៉ាយ-លុត នាយកមន្ទីរជាតិប្រៃសណីយ៍និងទូរគមនាគមន៍, លោកវរសេនីយត្រី យ៉-ប៊ូ, លោកង៉ោ-ស៊ុចាយ, លោកជ័យ-មៀច, លោករ៉ាយ-ប៊ុក អធិបតីសមាគមមិត្តពុទ្ធិកវិទ្យាល័យ, លោកអនុសេនីត្រី ប៉ាន់ នឹងអស់លោកឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយពុំបានរាប់នាមឲ្យសព្វគ្រប់ ៗ សូមជ្រាបថា ម៉ោង៩ ដែលបានកំណត់តាមកម្មវិធីដល់ហើយ, ព្រះសង្ឃទាំងឡាយក៏បាននិមន្តមកជាហូរហែ តាមសេចក្ដីនិមន្តដែលគេបានចាត់ធ្វើ ពីពេលមុន ទើបព្រះញាណកោសល ញាណ-ឈឹន និមន្តព្រះសង្ឃ៥អង្គទៅលើធម្មកុដិ ដើម្បីប្រគេនសម្ដេចរាប់បាត្រ ៗ លុះព្រះសង្ឃទាំង៥អង្គនិមន្តទៅដល់ហើយ, សម្ដេចដែលមានព្រះតេជព្រះគុណ ព្រះញាណកោសល ព្រះពុទ្ធវង្ស កៅ-ស៊ុម ព្រះវរសត្ថាពេជ្រគុល និងព្រះសង្ឃគ្រហស្ថឯទៀតនៅអមផង, មុននឹងរាប់បាត្រ សម្ដេចមានព្រះពុទ្ធដីកាថា ដោយមានព្រះសង្ឃជាប្រធាន, ខ្ញុំសូមផ្សាយកុសលដែលកើតអំពីចង្ហាន់បិណ្ឌបាត្រនេះ បំពោះពពួកសត្វទួទៅក្នុងត្រៃលោក, សូមឲ្យសត្វទាំងនោះបានសេចក្ដីសុខ កុំបីមានចិត្តចងអាឃាតព្យាបាទដល់គ្នានឹងគ្នា គប្បីតែរក្សាសន្ដានរវាំងបាណៈដូចគ្នា ? ទើបរាប់បាត្រជាខាងក្រោយ ៗ កាលបានទទួលចង្ហាន់បិណ្ឌបាត្រគ្រប់គ្រាន់ហើយ, ព្រះវិន័យធរ ឯក-ញឹម វត្តពិកទូវង្ស ជាប្រធានសង្ឃក្នុងពេលនោះ បានប្រណម្យអញ្ជលីធ្វើសច្ចកិរិយាបួងសួងសូមឲ្យសម្ដេចសះស្បើយចាករោគាពាធ ដែលបៀតបៀនក្នុងព្រះសរីរកាយសព្វថ្ងៃនេះយ៉ាងឆាប់រួសរាន់ ទើបស្វាធ្យាយធម៌ជាពរ ៣ មេទៀត

ប្រគេនចំពោះសម្តេច ៗ ឯគ្រូហស្ថទាំងឡាយ, កាលដែលសម្តេចបានរាប់បាត្រព្រះសង្ឃ៩អង្គមុន, ក៏ចាប់រាប់បាត្រប្រគេនព្រះសង្ឃដែលបាននិមន្តមកពីវត្តក្រៅ គ្រប់គ្រាន់គ្រប់ ៗ អង្គហើយ ឃើញថានៅមានអាហារភោជនជាច្រើន ទើបលោកប្រធានបានចាត់ឲ្យលោកធម្មានុរក្ស ស្រី-ធន និមន្តព្រះសង្ឃក្នុងវត្តទាំងអស់មកទទួលចង្ហាន់បិណ្ឌបាត្រជាបន្តទៅទៀត ដរាបដល់ម៉ោង១០ទើបចប់សព្វគ្រប់ ៗ

គួរឲ្យមានសេចក្តីសរសើរជាពន់ពេក, តាមការស្មានរបស់យើងថាចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជូនល្មមដល់ព្រះសង្ឃ៧៨អង្គ ដែលនិមន្តមកពីវត្តក្រៅប៉ុណ្ណោះ, នេះមិនដូច្នោះ ចង្ហាន់បិណ្ឌបាតបានគ្រប់គ្រាន់ដល់ភិក្ខុ សាមណេរទាំងអស់ក្នុងវត្តថែមទៀត ៗ

នៅពេលបញ្ចប់ការបិណ្ឌបាត, ព្រះសង្ឃទាំងឡាយបានស្វាធ្យាយធម៌ ប្រគេនជូនសព្វសាធុការពរចំពោះសម្តេចទំាងទាយកទាយិកាទាំងឡាយគ្រប់ឋានៈ ៗ បន្ទាប់ពីនោះ លោកម៉ម-ម៉ៃប្រធានគណៈកម្មការវត្ត បានថ្លែងសេចក្តីទទួលអំណរតាម៖គេក្បាសនស័ព្ទ តាំងនាមនៃសិស្សានុសិស្សទាំងអស់ដូចមានខាងក្រោម :

ថ្ងៃនេះ ជាតិថីមាឃបុក្សស្រន្តថាជាអភិលក្ខិតសម័យដ៏ប្រសើរ ដែលព្រះតេជព្រះគុណទាំងអស់លោកអ្នកទាំងឡាយ បានអញ្ជើញមកជួយអបអរសាទរបុណ្យគតញ្ញូចំពោះសម្តេចជាគ្រូនៃយើងរាល់គ្នាក្នុងពេលនេះ ៗ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការអញ្ជើញមកនៃព្រះតេជព្រះគុណទាំងអស់លោកទាំងឡាយ ៗ យើងទាំងអស់គ្នាដឹងហើយ សង្ខារៈក្នុងលោកសន្និវាសទាំងមូល តែងតែវិនាសទៅវិញជាធម្មតា គ្មានសង្ខារៈណាដែលមានឥទ្ធិពលមកជំទាស់រាំងគាំងនឹងវិបរិណាមធម៌បានឡើយ តែយើងបានដឹងបន្តិចទៅទៀតថា គុណធម៌អាចជួយបង្កើនអាយុសព្វសត្វឲ្យចំរើនបាន

ដោយអន្ទើ ព្រោះហេតុនោះ ទើបយើងពលគ្នារួមគំនិតធ្វើបុណ្យកតពានេះឡើង ជាកិច្ចតបឧបការគុណ ជាកិច្ចនៃអាយុវឌ្ឍនមង្គលផង ចំពោះសម្តេចជាគ្រូនៃយើងពលគ្នា ។

បពិត្រសម្តេចជាទីគោរព !

ឧបការគុណដ៏ធ្ងន់របស់សម្តេច ដែលផ្សាយមកដណ្តប់យើងខ្ញុំពលគ្នា ដោយព្រះទ័យប្រោសប្រោណជាពន់ពេកនោះ យើងខ្ញុំគ្មានអ្វីតបឲ្យសមគួរទេ ក្រៅពីកុសលធម៌ចេញ ដូច្នេះ យើងខ្ញុំព្រះករុណាទាំងឡាយ សូមបង្អោនកាយវាចាចិត្ត លើកករប្រណម្យផ្គងលើសិរសាទ្រកុសលទាំងនេះប្រគេនចំពោះសម្តេច, សូមសម្តេចជាម្ចាស់មេត្តាប្រោសអនុគ្រោះទទួលយកកុសលដែលសិស្សគណឧទ្ទិសប្រគេននេះ ដោយព្រះទ័យដ៏សោមនស្សចុះ ។

ដោយតេជានុភាព នៃកុសលចរិយាដែលកើតពីដួងចិត្តដ៏បរិសុទ្ធរបស់យើងពលគ្នានេះ, សូមសម្តេចបានសះស្បើយចាកព្រះរោគាពាធដែលមានក្នុងកាយសព្វថ្ងៃជាបន្ទាន់ឆាប់រួសរាន់តាមពាក្យបន់ស្រន់នៃយើងខ្ញុំនេះ, សូមសម្តេចមានព្រះជន្មាយុជាងរយវស្សា គ្រាន់ជាម្លប់ជាទីជ្រកកោននៃយើងខ្ញុំព្រះករុណាទាំងឡាយ ។

ម្យ៉ាងទៀត យើងសូមឧទ្ទិសកុសលនេះ ដល់សត្វក្នុងភាជនលោក សូមឲ្យមានបុញ្ញភាគីស្មើៗគ្នា កុំបីឃ្លៀងឃ្លាត !

អស់លោកជាកល្យាណមិត្រ, ជាសិស្សគណ, ជាឧបាសិកាទាំងឡាយ ! សូមឲ្យបានប្រកបដោយសេចក្តីសុខក្សេមក្សាន្តតាំងពីបច្ចុប្បន្ននេះ រហូតដល់អវសានជាតិគឺព្រះនិព្វានកុំបីឃ្លាត !!

ជាទីបំផុត, លោកប្រធានបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះព្រះតេជគុណ

នៅអធិការវត្តស្ទឹង ព្រមទាំងបរិស័ទចំណុះវត្ត ដែលបានអញ្ជើញទីនិមន្តមកធ្វើបុណ្យកតញ្ញូចំពោះសម្តេច ទាំងបានប្រគេនជូនសព្ទសាធុការជាច្រើន ហេតុឲ្យបានសម្រេចព្រះនិព្វានក្នុងអវសានជាតិ ។

នាមអស់លោកជាម្ចាស់ទេយ្យទាន

អស់លោកដែលបានប្រគេនទេយ្យទានចំពោះព្រះមហាថេរទាំង ១០ព្រះអង្គ ដែលស្វាធ្យាយធម៌ជយន្តោពីល្ងាចនៃសៅរ៍ នោះគឺ ។

១– ព្រះញាណកោសល ញាណឈឿន ១ រណ្តាប់

២– ព្រះពុទ្ធវង្ស កៅ-ស៊ុម ១ "

៣ លោកព្រះរាជអាជ្ញា អេង-សុទ្ធ ១០ "

៤– លោកវរសេនីយត្រី យ៉េ-ប៊ូ ២ "

៥– លោកស្រី ហុង-ថោង ១ "

៦– ព្រះគ្រូ ឃុន-ឃួន បច្ច័យ ១០០៛

៧– អ្នកស្រី កាន់-យ៉ុង " ៥០៛

សូមជ្រាបថា គោលបំណងដែលយើងកល់គ្នាធ្វើបុណ្យកតញ្ញូក្នុងឱកាសនេះមាន ៣ យ៉ាងគឺ

១– តបឧបការគុណចំពោះសម្តេច,

២– ប្រមូលគុណធម៌ជួយផ្សះព្រះរោគសម្តេច,

៣– ជាកិច្ចផ្សាយដំណឹងឲ្យក្រុមសិស្សជិតឆ្ងាយជ្រាបថាសម្តេចមានព្រះរោគាពាធប្រចាំនៅក្នុងព្រះអង្គកាយ តឹងតែងក្នុងការព្យាបាលជាពន់ពេកណាស់ ។

ចប់



# សាសនាជេន និងពុទ្ធសាសនា (គ)

គម្ពីរជេនបានពោលថា សាស្ដានេះប្រព្រឹត្តធ្វើទុក្ករកម្មយ៉ាងខ្លាំងក្លាហើយដាច់ខាត មិនអើពើដល់ការសុខទុក្ខរបស់រាងកាយ-រដូវរងាអង្គុយកន្ទប់ត្រជាក់ រដូវក្ដៅអង្គុយហាលថ្ងៃ, ប្រព្រឹត្តអាក្រាត អត់អាហារ អត់ទឹកជាដើម, គឺប្រព្រឹត្តយ៉ាងតឹងរឹងនូវអត្តកិលមថានុយោគ ដើម្បីកំចាត់បង់នូវកិលេសនិងបាបធម៌គ្រប់យ៉ាង-ព្រោះហេតុនោះទេវតាឲ្យឈ្មោះថាមហាវីរៈ ។

បណ្ឌិត អមរចន្ទ បានសរសេរបន្ថែមថា តាមគម្ពីរពុទ្ធសាសនា គេច្រើនហៅសាស្ដានេះថា «និគណ្ឋ នាដបុត្រ» ។ ពាក្យថា «និគណ្ឋៈ» បានសេចក្ដីថា «ខាងក្រៅគឺកាយពុំមានសំពត់ (អាក្រាត), ខាងក្នុងគឺចិត្ត រួចចាកចំណងក្នុងលោក» ។

ពួកអ្នកបួសតាមសាស្ដានេះហៅថា និគណ្ឋ ឬ និគណ្ឋសាវ័ក, ពួកគ្រហស្ថ ហៅថា សមណោបាសកា; ឬ ហៅរួមទាំងបព្វជិតទាំងគ្រហស្ថថា និគណ្ឋសាវ័កក៏បាន ។ ម្យ៉ាងទៀតគេហៅសាស្ដានេះថា «ជិនៈ» ព្រោះជាអ្នកឈ្នះកម្មដែលជាសត្រូវធំបំផុតរបស់ចិត្ត ។ មកពីពាក្យថា «ជិនៈ» នេះ ទើបគេហៅសាសនារបស់សាស្ដានេះថា «សាសនាជេន» ។

តាមវណ្ណគតិរបស់សាសនាជេន គេហៅសាស្ដានេះដោយឈ្មោះដទៃទៀតថា «វីរៈ, អតិវីរៈ, សម្មតិ, សិទ្ធៈ, មុត្តៈ» ដូច្នេះក៏មាន ។

ជេនិកសាវ័កបានពោលថាឈ្មោះទាំងនេះ គេបានហៅឲ្យសមទៅតាមចរិយា, ការប្រព្រឹត្ត នឹងការត្រាស់ដឹងរបស់សាស្ដានេះ ។ យើងជាពុទ្ធសាវ័ក ក៏ពុំអាចបដិសេធពាក្យរបស់គេបានទេ ។

## មហាវីរៈកាលនៅជាកុមារ

កាលនៅក្មេងមហាវីរៈក៏ជាកុមារមួយរូបប្រកបដោយអភិនិហារឥទ្ធិពលខ្លាំងណាស់ដែរ ។ មានរឿងដំណាលក្នុងគម្ពីរជេនថា ថ្ងៃមួយកាលដែលមហាវីរៈកំពុងលេងកីឡាជាមួយនឹងមិត្តក្នុងទីបរិវេណនៃនិវេសនដ្ឋាន, មានដំរីចុះប្រេងដ៏ខ្លាំងក្លាដេញសំដៅមករកមហាវីរៈ នឹងមិត្តដែលកំពុងលេង ។ ពួកកុមារជាមិត្តទាំងឡាយបានរត់គេចទៅកាន់ទីផ្សេងៗ បោលមហាវីរៈនៅតែម្នាក់ឯង ។ មហាវីរៈ ក៏ពុំមានតក់ស្លុតអ្វីទេ ប្រុងស្មារតីយ៉ាងរឹងប៉ឹង តទល់នឹងដំរី, លុះដំរីមកដល់, ក៏យកដៃចាប់ប្រមោយដំរីជ្រមុចចុះ ហើយលោតឡើងជិះដំរីធ្វើព្រងើយ ។

មហាវីរៈជាកុមារមានរូបល្អប្រិមប្រិយ សុភាពរាបសារ គួរជាទីគាប់ចិត្តនៃនារី, មាន

បញ្ញាឈ្លាសវៃចិត្តក្លៀវក្លា តាំងពីកំណើតមហាវីរៈមានការបេះដូងឥតទើសទាល់ ។

មហាវីរៈបានរស់នៅក្នុងបរិយាកាសនៃព្រះរាជវាំងដ៏សុខស្រួល ។ ប៉ុន្តែតែងពិចារណាឃើញវិសភាពនៃប្រជាជនក្នុងសង្គមជារឿយ ។ ការប្រកាន់វណ្ណៈ ខ្ពស់ទាប, ការប្រើទោសៈ, ការកំហែងសង្កត់សង្កិនមើលងាយត្រកូលទាប ។ ជាដើមប្រាកដដូចជាគម្រង់សំអុយឬបន្ទាចាក់ចុចក្នុងក្អៃកនៃមហាវីរៈ ។ ដើម្បីរលាស់ខ្លួនឲ្យផុតអំពីបំណងតាំងនោះ និងដើម្បីស្វែងរកអធិបតេយ្យ សមភាពដល់សង្គម មហាវីរៈគិតចេញចាកផ្ទះ ស្វែងរកធម៌ពិត តាំងពីនៅជាកម្លោះក្មេង ។ ប៉ុន្តែមាតាបិតា បានដឹងចិត្តគំនិតអផ្សុកអផ្សុកនោះ ក៏ព្យាយាមនិយាយលួងលោមអង្វរកូន ដោយការត្អូញត្អែរអំពីភាពចាស់ជរាបស់ខ្លួនជាដើម ។ មហាវីរៈដោយភាពជាអ្នកប្រកបដោយកតញ្ញូធម៌និកអាណិតអាសូរមាតាបិតាក្រៃពេក ក៏ទទួលយល់ព្រមតាមពាក្យអង្វរហើយតាំងចិត្តថានឹងចេញបួសក្នុងពេលណាដែលមាតាបិតាទិវង្គតហើយ ។

ដើម្បីទាក់ចិត្តមហាវីរៈឲ្យជាប់នៅក្នុងលោកវត្ត, ក្រោយមកមាតាបិតា បានរៀបផ្សំផ្គុំមហាវីរៈជាមួយនឹងអ្នកអង្គម្ចាស់ស្ត្រីម្នាក់ដ៏មានរូបល្អឆើតឆាយផុតគេ ឈ្មោះនាងយសោទាក្នុងគោណ្ឌញ្ញគោត្រ ។ ក្រោយមកបានធីតាមួយរូបឈ្មោះនាងអនុជាឬប្រិយទស្សនា ។ ធីតានេះបានទទួលរៀបអាពាហ៍ពិពាហ៍ជាមួយឧត្តមបុរសម្នាក់ឈ្មោះជមាលីដែលក្រោយមកបានជាសាវកនៃបិតាក្មេករបស់ខ្លួន, ប៉ុន្តែនៅទីបំផុតពុំដឹងជាដោយហេតុអ្វីបានជាទៅប្រឆាំងគ្នាទៅវិញ ។ ជមាលីនិងនាងប្រិយទស្សនាបានធីតាមួយរូបទៀតឈ្មោះនាងយសោមតីឬសេសវតី ។

តទៅទំព័រទី៣៤

# ពិធីបុណ្យឆ្លងឆ្លងសង្គាយនា (តនិងចប់)

កាលបរិច្ឆេទបុណ្យបានចាត់ចែងនៅក្នុងព្រះមហាបាសាណគុហាដូចមានតទៅនេះ

ក–) ថ្ងៃ១៣កើតខែពិសាខ ព.ស.២៤៩៩ (២២ឧសភា គ.ស. ១៩៥៦) ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១០បុណ្យបញ្ចប់សង្គាយនាផ្នែកវិន័យបិដក ពេលល្ងាចពីម៉ោង១ដល់ម៉ោង៤ ប្រគេនសៀវភៅព្រះត្រៃបិដកហើយនិងវត្ថុផ្សេង ៗ ដល់ព្រះសង្ឃជាសង្គីតិការកៈ ៗ

ខ–) ថ្ងៃ ១៤ កើតខែ-ឆ្នាំដដែល (២៣ឧសភា គ.ស.១៩៥៦) ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១០ បុណ្យបញ្ចប់សង្គាយនាផ្នែកសុត្តន្តបិដក ពេលល្ងាចបំបួសសាមណេរ ២៥០០អង្គចាប់តាំងពីម៉ោង៤ទៅ ៗ

គ–) ថ្ងៃ ១៥ កើតខែពិសាខ ព.ស.២៥០០ (២៤ឧសភា គ.ស.១៩៥៦), ពេលព្រឹកពីម៉ោង ៨ ដល់ម៉ោង ១០ បុណ្យបញ្ចប់សង្គាយនាផ្នែកអភិធម្ម, ពេលល្ងាចពីម៉ោង១ដល់ម៉ោង៤ប្រគេនសៀវភៅព្រះត្រៃបិដកនិងវត្ថុផ្សេង ៗ ដល់ព្រះសង្ឃជាសង្គីតិការកៈ ៗ

នៅវេលាម៉ោង ៤ ល្ងាចថ្ងៃដដែល ប្រគេនវត្ថុទាននិងសញ្ញាបត្រដល់ភិក្ខុសាមណេរ ដែលប្រឡងខាងអភិធម្មសូត្រមាត់ទទេ នៅក្នុងមន្ទីរចាត់ការពុទ្ធសាសនសភា ៗ

ថ្ងៃដដែលនោះទៀត វេលាម៉ោង៥ល្ងាច ធ្វើបុណ្យពិសាខបូជានៅខាងលិចសង្គិគុរចេតិយ (ស្វេទ[១]គុនចេតិយ) ៗ

ឃ–) ថ្ងៃ១-២ រោចខែពិសាខ ព.ស.២៥០០(២៥-២៦ ខែឧសភា គ.ស.១៩៥៦) ប្រគេនវត្ថុទានដល់ព្រះសង្ឃ២៥០០អង្គតាំងពីម៉ោង ១ ដល់ម៉ោង ៤ ល្ងាច ៗ

ង–) ថ្ងៃ ៣ រោចខែពិសាខ ព.ស. ២៥០០ (២៧ ឧសភា គ.ស. ១៩៥៦) ពេល

---

(១) ចេតិយនេះជារបស់ជាតិមនពីដើម; មានហៅថាទះគើង

ល្ងាចពីម៉ោង១ដល់ម៉ោង៤, អនុមោទនាផ្កាយកុសលនៃបុណ្យបញ្ចប់ឆដ្ឋសង្គាយនា នាទីន បុណ្យពុទ្ធជយន្តី ៗ ប្រគេនសញ្ញាប័ត្រតាំងអគ្គមហាបណ្ឌិតដល់ព្រះមហាថេរជាតិភូមា នឹងប្រគេនសញ្ញាប័ត្រអភិធជមហារដ្ឋគុរុ ចំពោះសម្តេចព្រះមហាសុមេធាធិបតីសង្ឃនា-យកគណៈមហានិកាយប្រទេសខ្មែរ, ព្រះវនរ័ត៌កិត្តិសោភណ៍សង្ឃនាយកគណៈមហានិកាយប្រទេសថៃ, ព្រះសង្ឃនាយកគណៈស្យាមនិកាយប្រទេសស្រីលង្កា, សម្តេចព្រះសង្ឃនាយកប្រទេសលាវ ៗ ពិធីបុណ្យបានចប់ស្រេចនៅវេលាម៉ោង៤ល្ងាច ៗ

កិច្ចប្រគេនវង្កាន់នៅក្នុងព្រះមហាបាសាណគុហានោះ គេរៀបវត្ថុសម្រាប់ប្រគេនជាបីជួរវែង ៗ ហើយម្ចាស់ទេយ្យវត្ថុមានលោកប្រធានាធិបតី អ៊ូ បា អ៊ូ នឹងលោកនាយកអ៊ូនុ ជាដើមបានឈរចាំប្រគេនជាជួរនៅខាងចំហៀងវត្ថុទាំងនោះ, ឯភិក្ខុសង្ឃនិមន្តជាជួរទៅទទួលទេយ្យវត្ថុ ក្នុងលោកមួយអង្គ ៗ មានវេយ្យាវច្ចករឬកប្បិយការកៈពីរនាក់កាន់កញ្ចោមួយម្នាក់ដើរតាមពីក្រោយខ្នងលោក ដើម្បីជួយកាន់ទេយ្យវត្ថុដែលពុទ្ធបរិស័ទប្រគេនលោករួចហើយ ៗ បុណ្យប្រគេនទេយ្យវត្ថុយ៉ាងធំមានពីរថ្ងៃគឺថ្ងៃ ១-២ រោចខែពិសាខព.ស.២៥០០ (២៥-២៦ ឧសភា គ.ស.១៩៥៦) ពីម៉ោង១ដល់ម៉ោង៤ល្ងាច ៗ

ហេតុដ៏ប្លែកក្រៃលែងប្លែកចិត្តដែលខ្ញុំបានស្មានទុកថាគេអាចធ្វើបាននោះគឺនៅថ្ងៃ ២ រោចខែពិសាខជាថ្ងៃប្រគេនទេយ្យវត្ថុយ៉ាងធំមានភ្ញៀវកិត្តិយសជាច្រើនដូចយ៉ាង ឯ.ឧ. ទី-គឹមសួ ឯកអគ្គរាជទូតប្រទេសខ្មែរប្រចាំប្រទេសថៃ-ភូមា; ឯ.ឧ.ឯកអគ្គរាជទូតប្រទេសថៃ ប្រចាំប្រទេសភូមា នឹងពួកទូតបរទេសជាច្រើន ក៏បានទៅជួបជុំក្នុងពេលប្រគេនវង្កាន់នោះដែរ ៗ

ពេលនោះគេសង្កេតឃើញលោក សាវ-ស្វែតក អតីតប្រធានាធិបតីប្រទេស

ភូមា, លោក ឧ-ចាន់-ធុន ចាងហ្វាងផុតលេខនៅសាលាកាត់ក្តីជាន់ខ្ពស់ប្រទេស-ភូមា, ឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសភូមា បាននាំគ្នាជួយសែងកញ្ចៅបែកញើសរហាមដើរតាមក្រោយព្រះសង្ឃទាំងនោះ ជាមួយក្រុមវេយ្យាវច្ចករប្រមាណ ៥០០ នាក់ ដែលសុទ្ធតែពួកភ្នាក់ងាររាជការនិងសមាគមផ្សេងៗ ។

គួរឲ្យនឹកស្ញើចទឹកចិត្តជ្រះថ្លានៃលោកអតីតប្រធានាធិបតី សាវ-ស្វេតែក ជាពន់ពេក ដែលលោកអាចប្រើពងកាយលោកឲ្យធ្វើដូច្នោះបាន ព្រោះលោកនោះឯងមានសន្តានចិត្តជ្រះថ្លាជក់យ៉ាងមាំក្នុងព្រះពុទ្ធសាសនា, សូម្បីកាលដែលសម្តេចនិមន្តទៅទីនោះកាលតតិយសន្និបាត លោកអតីតប្រធានាធិបតីតែងមកគាល់សម្តេចស្ទើរតែពុំលោះខានល្ងាចណាមួយ ។

អំពីរោងតាំងវត្ថុផ្សេងៗក្នុងពេលបុណ្យ

នៅទិសអគ្នេយ៍ព្រះមហាបាសាណគុហាក្នុងរបងនៃទួលសិរីមង្គលា គេឃើញរោងជាជួរយ៉ាងវែងៗដែលនៅក្នុងរោងទាំងអស់មានរៀបតាំងវត្ថុផ្សេងៗ ដើម្បីដាស់គំនិតប្រជាជនចំពោះកិច្ចការព្រះពុទ្ធសាសនានិងកិច្ចការរដ្ឋ ។

រោងតាំងទាំងនោះមាន២៨ខ្នងគឺ៖

ទី ១— រោងតាំងលោហធាតុផ្សេងៗ ដែលកើតពីថ្មដូចជា មាស-ពេជ្រ-សំណ-ទង់ដែង-ប្រាក់ (ល) ។ គេយកថ្មទាំងដុំនឹងថ្មកិនស្រេចដែលរៀបនឹងយកជាតិលោហធាតុទាំងនោះចេញមកតាំងឲ្យមើលនឹងផែនទីប្រាប់ទីកន្លែងកើតលោហធាតុនោះៗ ។

ទី ២— រោងតាំងគ្រឿងចក្រធ្វើស្ករអំពៅ, គ្រឿងចក្រវេញខ្សែក្រចៅ, គ្រឿងចាក់ត្បាញបាវ, កាដន់ខ្នុកម្រក្សណ៍វិចិត្រដោយក្បាច់ក្បូរបែបទំនើបប្លែកៗ ពីគ្នានឹងសំ-

ពត់ព្រក្សាផ្សេងៗដែលជាសម្បត្តិធ្វើកើតក្នុងប្រទេសកម្ពុជា ។

ទី ៣– ពេនតាំងផែនទីរូបនិយមនៃប្រទេសកម្ពុជា រចនាដោយដីស្អិតពេញផ្ទៃពេនតាំងមូល មានធ្វើរូបផ្ទះសំណាកតូចៗ នឹងបង្គោលខ្សែភ្លើងពេញជុំវិញទីក្រុង, ឯស្រុកស្រែមានពួកអ្នកស្រែខ្លះកំពុងដឹកកណ្ដាប់ស្រូវ ខ្លះកំពុងកិនស្រូវ អ្នកខ្លះកំពុងភ្ជួរដី, មានរូបម្នាក់ទៀតឈរបោះជំហានយ៉ាងមាំកាន់ទង់ជាតិកម្ពុជា ។ នៅលើដំបូលពេនតាំងនោះមានរូបបុរសម្នាក់ស្ត្រីម្នាក់កាន់កណ្ដាប់ស្រូវនៅដៃបែរមុខរកគ្នាយ៉ាងញញឹម ។

ទី ៤– ពេនតាំងរូបចម្លាក់បុរាណវត្ថុជាវិការនៃថ្ម, សិលាចារិកនឹងព្រះពុទ្ធបដិមាករសម័យបុរាណ ។

ទី ៥– ពេនតាំងរូបភាពវិវឌ្ឍនធម៌នឹងទេសភាពបុរាណ ។

ទី ៦– ពេនតាំងរូបភាពវិវឌ្ឍនធម៌នឹងទេសភាពសម័យបច្ចុប្បន្ននឹងអក្សរសាស្ត្រ ។

ទី ៧– ពេនតាំងផែនទីទ្វីបអាស៊ីពូនដីស្អិតធ្វើជារូបប្រៀប ហើយមានធ្វើរូបភិក្ខុសង្ឃនិមន្តទៅផ្សាយព្រះពុទ្ធសាសនាក្នុងប្រទេសនីមួយៗ គ្រង់ប្រទេសណាមានពុទ្ធសាសនាគេដាក់អំពូលភ្លើងពណ៌ផ្សេងៗពីគ្នា នៅលើទីនោះនឹងស្លាកប្រាប់ឈ្មោះប្រទេសនោះៗផង ។ នៅតាមជញ្ជាំងមានតាំងគំនូរពុទ្ធប្រវត្តិមួយចប់ ។

ទី ៨– ពេនតាំងក្បួនច្បាប់ពួកបច្ចិមប្រទេស ។

ទី ៩– ពេនតាំងគ្រឿងតុតាំងដែលធ្វើពីផ្ដៅនឹងវត្ថុផ្សេងៗជាច្រើនមុខទៀតដែលធ្វើកើតនៅក្នុងប្រទេស ។

ទី ១០– ពេនតាំងតែមប្រៃរបស់កម្ពុជានឹងប្រទេសក្នុងសាកលលោក សម័យបុរាណរហូតដល់បច្ចុប្បន្នកាលនេះ នឹងប្រដាប់ប្រដាខាងប្រៃសណីយ៍, ទូរលេខទូរស័ព្ទ(ល)

ទី ១១– ពេនតាំងក្បួនច្បាប់ទំនើបថ្មីៗផ្សេងៗ ដែលគេបានបកប្រែពីក្បួនច្បាប់

បច្ចិមប្រទេសមកជាភាសា ភូមា នឹងសៀវភៅក្បួនច្បាប់បុរាណជាច្រើន ។

ទី ១២– ពេលតាំងក្មេងជាតិភូមាសម័យបុរាណ ។

ទី ១៣– តាំងគ្រឿងវិទ្យាសាស្ត្រខាងសុខាភិបាល ។

ទី ១៤– តាំងកិច្ចប្រតិបត្តិការខាងសុខាភិបាលមានក្រុមគិលានុបដ្ឋាក–យិកាចាំព្យាបាលរោគ ហើយមានវិទ្យុកុនបញ្ចាំងពីអនាម័យនឹងរឿងរ៉ាវផ្សេងៗ ឲ្យមើលទាំងយប់ទាំងថ្ងៃ ។

ទី១៥– ពេលតាំងក្រុមមនុស្សខ្វាក់លេងភ្លេង អានអក្សរដោយស្ទាបចង្អុលដៃ នឹងត្បាញផ្តៅធ្វើកៅអី-គ្រែជាដើម ។

ទី១៦– ពេលតាំងមុខសេដ្ឋកិច្ចផ្នែកកប្បាស ។

ទី១៧– ពេលតាំងគ្រឿងឈើ មានផ្ទះធ្វើពីឈើយ៉ាងល្អៗជាបែបសង់ផ្ទះសម័យថ្មីៗ

ទី១៨– ពេលតាំងគ្រឿងប្រដាប់ធ្វើក្បឿង-ឥដ្ឋ, ផ្ទះអ្នកស្រែសម័យបុរាណនឹងផ្ទះអ្នកមានសម័យនេះ ។

ទី១៩– ពេលតាំងផ្ទះសម័យថ្មីក្នុងទីក្រុងនឹងបែបស្ថាបនាចំណតអាកាសយានដែលកំពុងតែធ្វើសព្វថ្ងៃនេះ ។

ទី២០– ពេលតាំងហិរញ្ញវត្ថុ នឹងការពិសោធន៍របស់ក្រុមអង្កេតការណ៍ នឹងគ្រឿងប្រដាប់ពិសោធន៍ផ្សេងៗ ។

ទី២១– ពេលតាំងវិទ្យុ–អំពូលវិទ្យុ–ទូរលេខ–ទូរស័ព្ទនឹងទូរទស្សន៍ ។

ទី២២–. តាំងកែវថ្លុះពិសោធន៍ការណ៍ផ្សេង ៗ នឹងកែវថ្លុះពីលើអាកាសយានមកលើផែនដី ។

ទី២៣– កន្លែងទឹកឈូរហូរចុះពីកំពូលភ្នំនឹងកន្លែងដុះសផុល – ស្ពានទាកប៉ាល់ជាថ្មី

នៅទីនោះគេធ្វើរូបប្រៀបកប៉ាល់ពីរជួសជុលរូបស្រូបចតអែបទីផែ ។

ទី២៤– រោងតាំងគ្រឿងចក្រផ្នែកសេដ្ឋកិច្ច មានម៉ាស៊ីនភ្ជួរដី, ម៉ាស៊ីនរាស់ដី, ម៉ាស៊ីនព្រួសស្រូវនិងច្រូតកាត់គោះស្រូវជាដើម ។

ទី២៥– រោងតាំងរបររកស៊ី សណ្ដែក-ថ្នាំ-អង្ករ ។

ទី២៦-២៧– រោងតាំងផ្នែកអក្សរសាស្ត្រនិងវប្បធម៌ដែលគណកម្មការបានរៀបចំឡើងនិងបកប្រែក្បួនច្បាប់ផ្សេងៗមកជាភាសាភូមា ។ គណកម្មការនោះមានលោកនាយករដ្ឋមន្ត្រី អ៊ូ-នុ ជាប្រធានបានកើតឡើងតាំងពីគ.ស.១៩៤៨ក្នុងកាលដែលប្រទេសភូមាបានឯករាជ្យថ្មីៗ ។

ទី២៨– រោងតាំងពីខ្សែរថភ្លើងនិងមានរូបរថភ្លើងតូចតូច ៗ រត់ពីទីក្រុងមួយទៅទីក្រុងមួយក្នុងប្រទេសភូមា ។

រោងដែលនៅមានក្រៅពីនោះទៀតគឺ មន្ទីរពេទ្យ៤កន្លែ, រោងល្ខោនសាធារណ៍៦កន្លែង, រោងចែកស្លាកបរិភោគអាហារ៤កន្លែង, រោងដប់លៀង៤កន្លែង, រោងលក់ដូរប្រមាណជាង២០និងទីស្នាក់ការក្រុមនគរបាល៦កន្លែង ។ នៅកន្លែងទាំង៦នោះមានបំពង់ទូរគ្យាសនស័ព្ទមួយ ៗ និងក្រុមនគរបាល៨នាក់ ៗ សម្រាប់ចាត់ការរក្សាបុណ្យនិងស្រែកហៅពុទ្ធមាមកជនដែលវង្វេងគ្នាឬកូនចៅ ។

ចំណែកខាងក្រុមកាកបាទ មានរថយន្តពេញដោយពេទ្យគិលានុបដ្ឋាយិកាបើកសន្សឹម ៗ គ្រប់ច្រកល្ហកដើម្បីជួយសង្គ្រោះអ្នកដែលមានជម្ងឺជាបន្ទាន់នៅពេលបុណ្យនោះឯង ។

ភិក្ខុ លី-គឹមឡុង (អគ្គធីរោ)
សមណនិស្សិតនៅធម្មទូតវិទ្យាល័យក្រុងរង្គូន ប្រទេសភូមា

# បុរាណគិរើសន៍ ( គ )

១– ចៅអធិការ (ល្វីឯម) ដែលយើងពោលថាមានកិត្តិស័ព្ទល្បីល្បាញខាងទេសនាជាវោហារកោសល្យនោះ គឺកាលសម័យដើមនៅក្នុងស្រុកព្រែកពោធិ៍ខេត្តកំពង់ចាមព្រៃវែង – នឹងខេត្តកណ្ដាលនេះ គ្មានអ្នកប្រាជ្ញបុរាណាចារ្យណាមួយ ចេះសំដែងធម៌ពន្យល់ធម៌ពិរោះក្បោះក្បាយញែកចែកសេចក្ដីឲ្យទូលាយឆ្ងាយ ស្ដាប់នោះពុំសូវមាន ទោះបើនៅស្រុកភូមិជិតឆ្ងាយដែលជាអ្នកមានការធ្វើបុណ្យទានហើយ តែងចូលមកនិមន្តទៅសំដែងធម៌ទេសនាមិនដែលសូវខាន, តែងសរសើរថាពិរោះស្ដាប់បានណាស់ ក៏សេចក្ដី យល់ការខុសត្រូវពិតប្រាកដ ចោមរោមស្រឡាញ់រាប់អានជាដរាបជឿស្ដាប់បង្គាប់មិនហ៊ានប្រព្រឹត្តធ្វើកន្លងធម៌នោះឡើយ សូម្បីទេសនាបុច្ឆា – វិសជ្ជនាទីងលោកធម្មថិកអង្គណា អង្គនោះ មានសេចក្ដីកោតខ្លាចពុំសូវហ៊ានប្រឆាំងក្នុងការសំដែងធម៌បុច្ឆាវិសជ្ជនានោះប៉ុន្មាន ទាល់តែល្បីព្រះនាមដល់ក្រុងភ្នំពេញថា ព្រះអាចារ្យ ( ល្វី-ឯម ) ជាអ្នកប្រាជ្ញប៉ិនប្រសព្វខាងការសំដែងធម៌ទេសនាដោយវោហារកោសល្យ គ្មានអ្នកណាផ្ទឹមជាគូបាន ។

២– ចៅអធិការ ល្វី-ឯម ដែលយើងពោលថា ខាងការបង្ហាត់បង្រៀនព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកនោះ គឺបានដឹកនាំភិក្ខុ-សាមណេរឲ្យហាត់ប្រែភាសាបាលីមកជាភាសាខ្មែរ ពេលព្រឹកបង្ហាត់ពីម៉ោង៧ដល់ម៉ោង១០ឈប់មួយលើក ពេលរសៀលបង្ហាត់ពីម៉ោង២ដល់ម៉ោង៥ឈប់មួយលើក ឯពួកអ្នករៀនក៏បានចូលទៅប្រែម្នាក់ម្ដង ៗ កំណត់ត្រឹម២៥មិនុតបានចំនួន៣សន្លឹក ហើយថយខ្លួនចេញមក ម្នាក់ចូលទៅប្រែទៀតបាន៣សន្លឹកដូចៗគ្នា បង្រៀនយ៉ាងនេះទាល់តែគ្រប់គ្នាទើបឈប់បង្ហាត់ លុះដល់ពេលថ្ងៃរសៀលម៉ោង៥កន្លះ នាំភិក្ខុសាមណេរធ្វើការសំអាតវត្តជាពល់ថ្ងៃ គឺឲ្យជញ្ជូនដី

ពីទីខ្ពស់មកចាក់ដាក់ទីទាប បង្រៀបឲ្យស្មើរធេងរលីងស្អាតសព្វអន្លើជាដើម, ឯភិក្ខុសាម-ណេរដែលមកនៅសំណាក់រៀនសូត្រនឹងវត្តនោះ សុទ្ធតែភិក្ខុ-សាមណេរភាគច្រើនខាងអាគន្តុកៈ គឺច្រើនមកពីស្រុកបាសាក់ព្រះត្រពាំងខ្លះ កណ្ដាលស្ទឹងខ្លះ បាត់ដំបងខ្លះ ក្រឡាញ់ទឹកជោរខ្លះ ទន្លេធំខ្លះ សិក្សារៀនសូត្រ ភាសាបាលីគ្រឹកគ្រេងសប្បាយរីករាយអស្ចារ្យហាក់ដូចជាវត្តលង្កានោះដែរ លុះដល់វស្សានដូវហើយ ចៅអធិការ ល្វី-ឯម ក៏បានចូលរៀនសមណធម៌ព្រះកម្មដ្ឋានពីសំណាក់លោកអាចារ្យនាម (អ៊ុង) ជាពល់ ៗ វស្សាពុំដែលដាច់ ទាល់តែមានកិត្តិស័ព្ទល្បីនាមថា យោគាចារ្យ អាចារ្យអ្នកមានសេចក្ដីព្យាយាមសមណធម៌ព្រះកម្មដ្ឋាន ទាំងបង្ហាត់បង្រៀនភិក្ខុ-សាមណេរ ឧបាសក ឧបាសិកាក្នុងកំឡុងខែត្រខណ្ឌវត្តនេះ គួរស្ងើច គួរឲ្យសរសើរថាជា « អគ្គាចារ្យ » អាចារ្យយ៉ាងចំណានប្រសើរក្នុងចំណោមនេះ ៗ

៣– ចៅអធិការ ល្វី-ឯម ដែលយើងពោលថា: ខាងការបង្ហាត់ធម៌សូត្រតាមគាណវារបាលីនោះ គឺសូត្រសង្កត់ត្រង់អក្ខរៈណាដែលមានតួព្យញ្ជនៈដម្រួតគ្នា ហៅថាសំយោគ ត្រូវទប់បង្អង់សំឡេងកន្លះមាត្រាហើយទើបសូត្រទៅគ្រប់តែព្យញ្ជនៈដែលមានតួអក្ខរៈដម្រួតគ្នា ឲ្យរត់មាត់ជាធ្នុងមួយដូចគ្នាគ្រប់វត្តក្នុងសង្គមស្រុកព្រែកពោធិ៍ទាំងមូល ដោយអំណាចតេជានុភាពសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ដែលទ្រង់មានព្រះសង្ឃដីកា បង្គាប់ឲ្យព្រះសង្ឃក្នុងសង្គមស្រុកព្រែកពោធិ៍ ឲ្យចូលមកហាត់របៀបសូត្រធម៌សំយោគពីសំណាក់ចៅអធិការល្វី-ឯម វត្តស៊ុធរ, កាលពេលបង្ហាត់ធម៌សូត្រជាសំយោគនោះ ចៅអធិការ ល្វី-ឯម បានចាត់ការបោះពុម្ពធម៌ធិតអពីចាហួយ តាមគាណវារបាលី ហើយបានផ្ទៀងផ្ទាត់ដោយត្រឹមត្រូវ ហើយចែកឲ្យទៅលោកគ្រូ

ចៅអធិការ នឹងលោកគ្រូសូត្រគ្រប់វត្តដែលបាននិមន្តមកហាត់សូត្រផ្ទាល់នឹងព្រះអង្គលោក ឲ្យមានរបៀបរៀបរយល្អខាងការសូត្រធម៌ក្នុងព្រះពុទ្ធសាសនា ទាល់តែបាននាមល្បីល្បាញថា: «សង្ឃគណាចារ្យ» អាចារ្យក្នុងក្រុមសង្ឃក្នុងសង្គមស្រុកព្រែកពោធិ៍នៅបច្តូគ្រាមនេះឯង ។

៤– ចៅអធិការ ល្វី-ឯម ដែលយើងពោលថា: ខាងការបង្ហាត់បង្រៀនពួកកុមារឲ្យសិក្សាអក្សរសាស្ត្រខ្មែរ តាមរបៀបសម័យដើមនោះ គឺបានចាត់វិធានការឲ្យភិក្ខុ ១ រូប ឬសាមណេរធំ ១ រូប ធ្វើជាគ្រូបង្រៀនពួកកុមារទាំងឡាយនោះៗ ដែលពួកជនជាមាតាបិតានាំយកបុត្រទាំងនោះ មកផ្ញើទុកដាក់ឲ្យនៅរៀនសូត្រផ្ទាល់នឹងព្រះអង្គលោកៗ ក៏ចាត់របៀបឲ្យបង្រៀនដូចតទៅនេះ ៗ

១– ឲ្យកុមារចាប់ក្ដាររៀនបីឱបនូវដៃៗ ស្ដាំកាន់ដីសសរសេរទន្ទេញថាតាមគ្រូបង្រៀននាំឲ្យរៀនថា: អ-អា ។ល។ អាំ-អះ សរសេរមាត់ទន្ទេញថាតាមតួព្យញ្ជនៈ ទាល់តែចាំស្ទាត់ហើយ ទើបឲ្យរៀនហាត់សរសេរ ក..ខ ។ល។ ឡ-អ សរសេរទាំងទន្ទេញចាំស្ទាត់ហើយ ឲ្យរៀនហាត់បំបែកតួព្យញ្ជនៈទាំង ៣៣ តួគឺ ក-កា . . . ១-ខា នឹងបង្ហាត់ផ្ញើផើងគឺ ក្យ-ក្យា ។ល។ ស្រ-ស្រា បង្រៀនយ៉ាងនេះ ទាល់តែកុមារនោះៗចេះចាំស្ទាត់ហើយ ទើបឲ្យមើលច្បាប់ប្រកបចំនួន ៤ សទ្ទិកស្ទីករដ្ឋគីប្រកបថា ក+ង មើលថា កង ដូច្នេះយ៉ាងនេះជាដើម ដរាបទាល់តែកុមារនោះៗយល់ពាក្យប្រកបច្បាស់លាស់ហើយ ទើបឲ្យរៀនមើលសាស្ត្រាច្បាប់ គឺរៀនមើលសាស្ត្រាច្បាប់ក្រមជាដើម, លំដាប់ទៅរៀនមើល កេរ្តិ៍កាល, ច្បាប់ប្រុស, ច្បាប់ស្រី, ស្វាសុត, ដាវរឿង, សុបិន, មុជ្ឈលិន្ទ, សង្ខសិល្បជ័យ, ព្រះលក្ខណវង្ស, នាគវ័ន, សមណ-

គោត្តម, ទេសន៍មហាជាតក៍ របៀបបង្រៀនមើលសាស្ត្រាវៀងនេះគឺរៀនមើលតាមបទបាទពាក្យកាព្យឃ្លោង សាស្ត្រាច្បាប់ណាជាបទបាទអ្វី ឲ្យមើលតាមបទពាក្យកាព្យនោះៗ ដូចបទកាកគតិ, បទព្រហ្មគីតិ, បទភុជង្គលីលា, បទពាំនោល, បទ-បន្ទោកាក ជាដើម ទាល់តែកុមារនោះៗចេះធ្វើបទតាមពាក្យកាព្យស្ទាត់ហើយ ទើបអនុញ្ញាតឲ្យបួសជាសាមណេរចូលរៀនប្រែភាសាបាលីព្រះត្រៃបិដកទៀត,

២– ពេលយប់ធ្វើតឲ្យសាមណេរ កុមារនមស្ការថ្វាយបង្គំព្រះរតនត្រ័យរួចសូត្រធម៌សត្តបរិត្តជានិច្ច ហើយឲ្យចយខ្លួនទៅនៅមន្ទីរសាលាចាស់ ១ ខ្នង រៀនកប់វិជ្ជាលេខតាំងពីលេខ១ ដល់លេខ ១០០, រៀនទន្ទេញធម៌តាំងពីធម៌សម្ពុទ្ធេ ។ល។ យេសន្តា រជ្ជ ជាដើម ធ្វើតែយ៉ាងនេះរាល់ពេលពុំដែលដាច់ មិនតែត្រឹមប៉ុណ្ណោះដល់វេលាថ្ងៃ៧-៨កើត ១៤-១៥កើត ៧-៨រោច ១៤-១៥រោច ព្រះអគ្គលោកខំធ្វៀតឲ្យឧបាទដាស់តឿនរំលឹកដល់ភិក្ខុ-សាមណេរ ដោយបំណែកធម៌ដទៃទៀតជាគ្រឿងបំភ្លឺពន្យល់ឲ្យស្គាល់យល់ច្បាស់នូវផ្លូវលោកផ្លូវធម៌ដែលជាឧត្តមគតិយ៉ាងពិត ដើម្បីឲ្យប្រតិបត្តិទៅតាមទំនួលរបស់ព្រះពុទ្ធសាសនា សូម្បីបច្ចាជនដែលកើតមកខាងក្រោយនៅឃុំស៊ីធរសព្វថ្ងៃនេះ ទុកណាជាមិនបានទាន់ឃើញធម្មចរិយានឹងសិក្ខាចរិយា ដែលចៅអធិការ លី-ឯម បានអប់រំទូន្មានប្រៀនប្រដៅភិក្ខុ-សាមណេរ កុមារព្រមទាំងឧបាសក-សិកាកុងសង្គមស្រុកវត្តអាពមស័យជាន់នោះ ក៏គង់អាចសំគាល់ចរិយារបស់ឧបាសក-ឧបាសិកាដែលជាសិស្សានុសិស្សជាន់ចាស់របស់លោកនៅសព្វថ្ងៃនេះ ឃើញថាមានកិរិយាមារយាទសណ្ដាប់ធ្នាប់ស្អាតត្រង់ល្អ ជាអ្នកប្រព្រឹត្តសីលធម៌រក្សាសីល ៥-៨-១០ មិនសូវរឹងទទឹងយល់ចាស់ចំពោះធម្មវិន័យ មានសេចក្ដីសង្រួមខ្ជាប់មិនសូវឃ្លើសឃ្លង់ជាអ្នកសន្សំខាង

ការរៀនសូត្រខាងការប្រតិបត្តិតាមព្រះពុទ្ធសាសនា គួរសរសើរនឹកគុណូបការចំពោះព្រះអង្គលោកថា: « អគ្គវិទយាចារ្យ » អាចារ្យអ្នកដឹកនាំយ៉ាងប្រសើររបស់យើង ។

៥– ចៅអធិការ ល្វី-ឯម ដែលយើងពោលថា: ខាងការរៀបចំវត្តស៊ីធរបានរុងរឿងនោះ គឺវត្តនេះមានសុទ្ធតែដើមឈើធំៗ ព្រៃស្តុកស្តុំស្តាញ ដើមបគ្គៅ ដើមចន្ទន៍ ដើមទ្រាំង (ខ្លង) កូនឈើតូចតាចស្មៅស្បូវដុះណែនណាន់តាន់តាប់ ដើមបន្ទាសស្អិតដុះរំពទ្ធប្រាង្គចេតិយជិតផងជិតតាំងពីដីដល់ទៅកំពូល ជាទីកន្លែងនៅនៃសត្វខ្លាធំ-តូចជ្រូកព្រៃ សូម្បីតែពេលថ្ងៃក៏គេមិនសូវហ៊ានដើរទៅជិតប្រាង្គនោះដែរ ។

(នៅមានត)

## ធនញ្ជយបណ្ឌិត (ត)

តស្មា ភយិមំ វិវិធំ សវេត្វា វេរំ ជហិត្វាន
រមេយ្យសីលំ អនន្តគុណញ្ច មហានិសំសំ សម្បត្តិទាំ
ជិន គោចរន្តិំ ។

ព្រោះហេតុនោះបុគ្គលជាសប្បុរសតែងរឭកនឹកឃើញនូវភ័យក្នុងវេរាទាំង៥ថា ជាមន្ទិលខ្លាំងយ៉ាងនេះហើយ លោកលះបង់ចេញឲ្យស្រឡះលោករមែងត្រេកអរចំពោះសីលទាំង៥ជាសីលមានអានិសង្សច្រើនជាអនន្តគុណជាទីគោចរនៃព្រះជិនស្រីជាទីញុំាងសម្បត្តិទ្រព្យឲ្យដល់ព្រមហើយតាំងនៅស្ថិតស្ថេរផង ។ លុះចប់ធម្មទេសនាយក្សមានចិត្តជ្រះថ្លាខ្លាំងណាស់ យក្សក៏ប្រណម្យអញ្ជលីក្រាបក្រោមបាទានៃធនញ្ជយពោធិសត្វ ហើយបញ្ចេញឧទានវាចាថា:

គណ្ហាមិ បញ្ចសីលានិ ឲ្យាលេយ្យន្តុំ សុនិ មលំ
ឯវំ សគ្គណ្ហិតុំ ធីរ សន្ធិ-វិហារគន្តិមំ ។

សេចក្តីថា៖ បពិត្រមហាបុរសមានព្យាយាមជាគ្រឿងទំលាយនូវវេរកាក្រក់ផ្សេងៗ ខ្ញុំសូមទទួលសមាទាន កាន់យកនូវសីល៥នេះ សូមមហាបុរសសង្គ្រោះដល់ខ្ញុំ ប្រៀនប្រដៅខ្ញុំជាកូនសិស្សផ្ទាល់ដៃ ខ្ញុំនឹងរក្សាសីល៥នេះឲ្យបរិសុទ្ធផុតមន្ទិលទាំងអស់ពុំឲ្យមានសៅហ្មងឡើយ ។ សូមឲ្យគាពដនាឲ្យសំដែងមលគរធម៌តទៅទៀត ។

ធនញ្ជយកុមារឲ្យសីលរួចហើយឈប់បន្តិច បង្គាប់យក្សទាំ ម្នាលយក្សអ្នកឯងចូរទៅឃោសនា ព្រះបាទធនញ្ជយគោរព្យរាជព្រមទាំងរាជបរិស័ទឲ្យចូលមកស្តាប់ធម៌ផង ហ្ន ! នៅក្នុងកុង៍ទីឯណោះ ទៅនាំយកទាំងអស់មកស្តាប់ផង ។ ស្តេចយក្សក៏ហោះស្ទុះទៅប្រកាសហើយនាំយកស្តេចព្រមទាំងបរិវារស្តេចមកដល់ក្នុម ។ ព្រះពោធិសត្វឃើញថាជួបជុំព្រះរាជា រាជបរិស័ទនឹងមនុស្សទេវតាមូលមកមីរដេរដាសពាសពេញក្រឡាមហាព្រៃពីហើយ តាំងសំដែងមលគរធម៌ជាបទគាថាយ៉ាងនេះថា:

ទិដ្ឋជ្ជុទ្ធ ទោសន្ធ កត្ថិ ថទ្ធតិ ទស
អហិរិកំ អនោតប្បំ លោកនាសយុត្ត
នេតេ កិលេសា ចិត្តក្លេសកា មលគរធម្មា នាមាតិ ។

ប្រែថា ធម៌ជាមន្ទិលសៅហ្មងគ្រឿងមន្ទិលមាន១០យ៉ាងគឺ ទិដ្ឋិយល់ខុស១ ថទ្ធបានទ្រព្យហួសហេតុ១ ទុទ្ធ: សេចក្តីវេរពៀយ១ ទោស: ខឹងប្រទូស្ត១ អន្ធ: ល្ងង់ល្ងិតខ្លួនឯងហើយនាំឲ្យគេល្ងិតល្ងង់ផង១ កត្ថិ ស្អាក់ស្មេរគុណព្រះរតនត្រ័យ១ ថីន: ប្រមូសកាយចិត្តធ្ងន់ធ្ងុលទទុយ១ ទតិ ធាប់ឡើងដំនោរ១ អហិរិកំ មិនខ្មាស់បាប១ អនោតប្បំ មិនព្រឺស្បើនឹងអំពើអាក្រក់១ ។ ត្រូវជា១០ ឈ្មោះថាមលគរធម៌ ព្រោះមន្ទិល

នេះឯងជាមន្ទិលយ៉ាងក្រៃលែងគ្មានអ្វីប្រៀបបានឡើយ ។

នរណាប្រព្រឹត្តល្ងង់តាមធម៌នេះហើយ អ្នកនោះមុខជាធ្លាក់ទៅអបាយភូមិជាក់ស្ដែងពុំខាន មិនអាចទៅកាន់សួគ៌និព្វានបានឡើយ ។

ហេតុនេះត្រូវបណ្ឌិតអ្នកប្រាជ្ញទាំងឡាយលះបង់បាបធម៌ទាំង១០យ៉ាងនេះឲ្យស្រឡះចេញទើបបានសុខសួគ៌និព្វានពុំឃ្លាតឡើយ ។

ធម្មទេសនា វសានេ លុះចប់ព្រះធម៌ទេសនាហើយសំឡេងទេវតានឹងមនុស្សថ្វាយសាធុការកងរំពងលាន់ឮឡើង ស្មើរគក្រើកផែនពសុធា ។ គ្រានោះយក្សក៏ឱនកាយថ្វាយបង្គំព្រះពោធិសត្វប្រគល់ខ្លួនជាកូនសិស្សដោយពាក្យប្ដេជ្ញាថា សូមមហាបុរសជាទីពឹងរបស់ខ្ញុំតាំងពីថ្ងៃនេះតទៅដរាបដល់អស់ជីវិត ។ ឯព្រះបាទធនញ្ជយកោរព្យរាជ ស្ដេចឱបថ្នាក់ថ្នមទ្រង់ពោធិសត្វដាក់លើធម្មាសនៈ មានព្រះឱង្ការថា ចាប់តាំងពីថ្ងៃនេះតទៅមានតែធនញ្ជយកុមារប៉ុណ្ណោះជាទីពឹងពុំនាក់យើងស្មើដោយជីវិត ។ ទើបនាំគ្នាហែហមព្រះពោធិសត្វចូលទៅកាន់នគរវិញហោង ។ លុះដល់នគរហើយ ព្រះរាជាទ្រង់ព្រះរាជបញ្ជាឲ្យគោះគងទូងកេរ៍ប្រជុំអស់នាហ្មឺនសព្វមុខមន្ត្រី មានធនញ្ជយសេដ្ឋីនឹងនាងសុខមាលីជាដើម ហើយព្រះអង្គតាំងរៀបពិធីអភិសេកធនញ្ជយកុមារជាព្រះរាជបុត្របុង្សរបស់ព្រះអង្គ ហើយប្រទានប្រាសាទខាងមុខបូរីឲ្យព្រះពោធិសត្វគង់នៅ ប្រទានរង្វាន់មួយថ្ងៃ១សែនកហាបណនឹងយសស័ក្តិជាធំព្រមទាំងពលពាហណៈដ៏ច្រើន ធ្វើស្រុកធំទាំងនោះឲ្យជាស្រុកនាំសួយឡើងបំពោះធនញ្ជយសេដ្ឋី ។ ធនញ្ជយបរមពោធិសត្វបានប្រកបលាភសក្ការៈនឹងសេចក្ដីពប់អានរបស់មនុស្សទេព្តានឹងឥស្សរភាពដ៏ធំឧត្ដមថ្កើងថ្កាន ល្បីល្បាញខ្ចរខ្ចាយផ្សាយទៅក្នុងដែនកុរុទ្វីបទាំងមូល

ជាអស្ចារ្យ ម្នាលភិក្ខុទាំងឡាយបញ្ញានេះមានប្រយោជន៍អាចញុំាងខ្លួនឯងឲ្យតាំងនៅក្នុងសុខភាពផង អាចញុំាងអ្នកដទៃឲ្យរួចអំពីគ្រោះថ្នាក់គ្រប់យ៉ាង ហើយតាំងនៅក្នុងសុខសុវត្ថិភាពផង ហេតុនេះត្រូវអ្នកទាំងឡាយ បំរើនបញ្ញាឲ្យមានបរិបូណ៌ឡើង ឲ្យដូចជាធនញ្ជយពោធិសត្វកំពុងសាងបញ្ញាបារមីនោះ បានដល់នូវសេចក្ដីសុខចំរើនទីងឋានៈជាធំផ្ទាល់ខ្លួន; ដោយការប្រដៅយក្សកំណាចឲ្យមានចិត្តស្លូតបូតត្រង់ល្អផង ទីងស្ដេចដែលដល់នូវទីអស់ទៅនៃព្រះជន្ម ឲ្យមានជីវភាពឡើងវិញបានផង ក្នុងបច្ចុប្បន្នទីងបរលោកនាយដូច្នោះឯង ៗ អ្នកមានប្រាជ្ញាគប្បីសន្និដ្ឋានចូលចិត្តចុះ ៗ

មលតរកជាទី១សន្ទើបប៉ុណ្ណោះ ៗ

---

## ជ័យប្រាជ្ញ (ត)

ពួកអស់អ្នក– សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាមែន ៗ

ព្រះមហាក្សត្រទ្រង់ព្រះតម្រិះថា បើប្រសិនជាអញមិនដេញដោលអាជ័យតទៅទៀត ជាហេតុនាំឲ្យពួកអស់អ្នកទាំងនេះ កើតសេចក្ដីក្ដៅក្រហាយនឹងអញ ដោយសំគាល់ថាអញកាន់ជើងអាជ័យ បើអញដេញដោយទៅទៀតក៏ឥតអំពើ ព្រោះហេតុផលនៃដើមចោទ នឹងចុងចោទចម្លើយឃើញថាស្របគ្នាអស់ទៅហើយ ល្មមឲ្យអាជ័យរួចខ្លួន ៗ

ប៉ុន្តែណើយចុះ ធម្មតាអ្នកសម្រេចសេចក្ដីត្រូវតែដេញដោលឲ្យអស់ជើង ទើបអ្នកម្ខាងអស់ចិត្ត យ៉ាងនេះត្រូវតែអញដេញដោលតទៅទៀត ៗ

ក្រោយដែលព្រះមហាក្សត្រទ្រង់ព្រះតម្រិះដូច្នេះ ទ្រង់ត្រាស់សួរទៅ កុមារជ័យ

ថា នែ! អាជ័យ! នេះគ្រាន់តែគេស្អប់មុខ អាឯងបញ្ចេញគូថមកឲ្យគេ ៗ ចុះបើគេថាស្អប់ខ្លួនអាឯងទាំងមូល តើអាឯងនឹងធ្វើកលឧបាយឲ្យគេដូចម្ដេចវិញ ៗ

កុមារជ័យ– សូមទ្រង់ព្រះមេត្តាប្រោស! ការនោះនឹងក្រាបទូលអំពីកលឧបាយនោះតែម្ដងមិនបាន ដោយហេតុមិនទាន់មានគេស្អប់បើមានគេស្អប់ នោះទើបក្រាបបង្គំទូលអំពីកលឧបាយនោះបាន ៗ មានសេចក្ដីឧបមាថា ធម្មតាជាងឈើក្ដី ជាងដែកក្ដី ជាងទងក្ដីជាងតម្បាញក្ដី ៗល ៗ កាលបើមិនទាន់មានវត្ថុសម្រាប់ប្រកបការទាំងឡាយតាមចំណេះនៃខ្លួននោះមកដាក់នៅក្នុងទីចំពោះមុខទេ មិនអាចនឹងរចនាឲ្យទៅជាបែបណាមួយបានឡើយ ព្រោះវត្ថុទាំងនោះជាគ្រឿងញុំាងជាងឲ្យប្រកបការទៅតាមចំណូលនៃខ្លួន មិនមែនជាងជាអ្នកញុំាងគ្រឿងទាំងនោះឲ្យប្រព្រឹត្តទៅតាមចំណេះនៃខ្លួនទេ ៗ ឯការប្រើកលឧបាយដើម្បីនឹងដោះបញ្ហាទាំងឡាយក៏មានសភាពដូច្នោះដែរ, សូមទ្រង់ជ្រាប ៗ

ព្រះមហាក្សត្រ– អើ! អញយល់បានហើយ ចុះត្រង់រូបអញម្ដេចក៏អាឯងសំឡឹងមើលដោយភ្នែកតាមប្រហោងយ៉ាងតូច ត្រង់អស់អ្នកហេតុអ្វីក៏អាឯង រមិលមើលដោយក្រប៉េះគូថតាមប្រហោងជញ្ជាំងយ៉ាងធំ ៗ

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស! ភ្នែកចាស់សម្រាប់មើលឃើញបានឆ្ងាយ ហើយក៏ច្បាស់ល្អផង ឯភ្នែកថ្មីពិតមែនតែធំ ប៉ុន្តែទូលព្រះបង្គំមិនអាចដឹងថារមិលមើលបានច្បាស់ឬមិនបាន មួយទៀតភ្នែកថ្មីគ្មាននរណាគេស្អប់ខ្ពើមផង ហេតុនេះបានជាទូលព្រះបង្គំឲ្យវារមិលមើល តាមប្រហោងជញ្ជាំងធំ ដើម្បីឲ្យបានច្បាស់លាស់ល្អ ៗ

ព្រះមហាក្សត្រ – នែ! អាជ័យ! ភ្នែកថ្មីដែលអាឯងបានធ្វើនោះ តើវាអាចនឹង

មើលឃើញមែន ឬយ៉ាងណា ? ។

កុមារជ័យ — ការនេះទូលព្រះបង្គំទើបតែនឹងធ្វើល្បងមើលជាដំបូង ត្រង់ភ្នែកនោះវាមើលឃើញមិនឃើញ ទូលព្រះបង្គំមិនបានដឹងដែរ ។ តែភ្នែកនោះអ្នកបង់ទាំងអស់ថា ពិតជាមើលទៅឃើញ បានជាអាចនាំសេចក្ដីនេះមកក្រាបបង្គំទូលព្រះអង្គតាមដំណើរទំនងនោះបាន ឯត្រង់ភ្នែកថ្មីនោះវាមើលឃើញមិនឃើញ មិនមែនជាភារៈលើទូលព្រះបង្គំទេ ឯទូលព្របង្គំគ្រាន់តែជាអ្នកធ្វើប៉ុណ្ណោះ នឹងក្រាបបង្គំទូលដោយបទណាមួយមិនបាន ។

ព្រះមហាក្សត្រ — ត្រង់ភ្នែកចាស់ម្ដេចក៏អាឯងដឹងថាមើលឃើញឬមិនឃើញ ចុះភ្នែកថ្មីម្ដេចក៏អាឯងមិនដឹង បើថាភ្នែកនោះជារបស់អាឯងទាំងអស់ ។

កុមារជ័យ — បពិត្រព្រះសម្មតិទេព ភ្នែកចាស់ជាភ្នែកកំណើតភ្នែកថ្មីជាភ្នែកធ្វើ ។ ធម្មតារបស់អ្វីក៏ដោយ តែធ្វើថ្មីហើយត្រូវតែមានការពិសោធន៍យ៉ាងនេះ ត្រង់បានផលមិនបានផលនោះមិនមែនអ្នកបង្កើតអាចកំណត់ បានទៅតាមទំនើងចិត្តរបស់ខ្លួនឡើយ លុះណាតែការនោះប្រាប់មកវិញ ទើបអាចនឹងកំណត់បាន ការថ្មីដែលប្រាប់មកវិញនោះយ៉ាងនេះ នឹងឲ្យក្រាបបង្គំទូលតាមពិតមិនបាន ;

សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រទ្រង់តម្រិះថាបញ្ហានេះបើអញដេញដោលទៅឃើញថា បើដល់ទៅទីបំផុតមុខជាអាជ័យមានប្រៀបជាង ព្រោះវាអាចនឹងឆ្លើយទំលាក់ទៅលើមាត់ដែលវាធ្វើនោះ ឲ្យឆ្លើយប្រាប់មកអញវិញ ហេតុនេះត្រូវសង្ខេបកាត់សេចក្ដីត្រឹមប៉ុណ្ណោះ លុះទ្រង់ព្រះតម្រិះដូច្នេះហើយទ្រង់វិនិច្ឆ័យដោយបទថាដូច្នេះ ៖

១ – នាងទាំងឡាយបានជាឲ្យអាជ័យយ៉ាងនេះមែន

២ – អាជ័យបានប្រព្រឹត្តតបនឹងសំដីនោះមែន ,

៣ – គូរវាទទាំងពីរបានប្រព្រឹត្តនូវអំពើរដោយផ្ទាល់ខ្លួន ដោយចេតនាជាបតិកិរិយាទៅវិញទៅមកដោយបទវាទ ដូច្នេះត្រូវតែទទួលការផ្សះផ្សា ឲ្យជានឹងគ្នាតទៅទើបត្រឹមត្រូវតាមមូលហេតុ ។ ទ្រង់ក៏មានព្រះបន្ទូលថា នែ ! គូវាទ ! ឯងបានសុខចិត្តជានឹងគ្នាឬទេ ?

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំសុខចិត្តជានឹងគ្នាហើយ ។ ពួកអស់អ្នកធ្វើមុខក្រញូវ នៅស្ងៀមគ្រប់គ្នា ។

ព្រះមហាក្សត្រ – ណ្ហើយអាជ័យ ! ឯងទៅផ្ទះបុះ អស់ការត្រឹមប៉ុណ្ណេះហើយ ។

កុមារជ័យ – នៅស្ងៀមមួយសន្ទុះដោយនឹកស្តាយថា បើព្រះមហាក្សត្រសួរអញតមកទៀត អញនឹងឆ្លើយថា ការនេះព្រះអង្គដដីកសួរទូលព្រះបង្គំឥតអំពើទេ ព្រោះទូលព្រះបង្គំចាំទទួលដំណឹងពីមុខថ្មីនោះ ដូចជាព្រះអង្គត្រូវការរង់ចាំទទួលដំណឹងពីទូលព្រះបង្គំដែរ ព្រោះទូលព្រះបង្គំបានធ្វើភ្នែកសម្រាប់ឲ្យវាមើល, បានធ្វើត្រចៀកសម្រាប់ឲ្យវាស្តាប់, បានធ្វើច្រមុះសម្រាប់ឲ្យវាដកដង្ហើម, បានធ្វើមាត់សម្រាប់ឲ្យវានិយាយប្រាប់មកទូលព្រះបង្គំវិញ តែវាមិនបានឲ្យដំណឹងមកសោះយ៉ាងនេះ ទូលព្រះបង្គំនឹងក្រាបបង្គំទូលតាមពិតមិនបាន ។ បើទ្រង់សួរមកទៀតថា អាឯង បានធ្វើវិញ្ញាណឲ្យវាទេ នោះអញនឹងឆ្លើយថា បំណែកវិញ្ញាណរបស់ទូលព្រះបង្គំទាំងប៉ុន្មានទូលព្រះបង្គំបានប្រគល់ឲ្យទៅវាទាំងអស់ ។ បើទ្រង់សួរថា វាបានទទួល ឬមិនបានទទួល នោះអញឆ្លើយថា មិនឮវាឲ្យដំណឹងមកវិញ ។ បើទ្រង់សួរថា ឯងឲ្យផ្ទាល់

ឬឲ្យយ៉ាងណា? អញឆ្លើយថា ឲ្យផ្ទាល់ ។ បើទ្រង់សួរថា បើឲ្យផ្ទាល់ម្ដេចក៏មិនដឹងថាវាបានទទួល ឬ មិនទទួល? អញឆ្លើយថា ការឲ្យរបស់ឥតរូប មិនអាចដឹងបានថាគេទទួល ឬ មិនទទួលឡើយ លុះណាតែគេបញ្ចេញភស្ដុតាងឲ្យឃើញ នោះទើបអាចដឹងបានថាគេទទួល ឬ មិនទទួល បើគេគ្រាន់តែនៅស្ងៀម នោះនឹងក្រាបទូលតាមពិតមិនបាន ។

ការនេះមើលទៅប្រហែលថា ទ្រង់មិនត្រាស់សួរតទៅទៀតទេ ។ បើទ្រង់ឈប់មានព្រះបន្ទូលសួរហើយ អញក៏មិនបានឈ្នះពេញទី ។ ប៉ុន្តែណ្ហើយចុះ! កុំស្ដាយ! បើអញបានឈ្នះពេលនេះប្រាកដជានឹងបានសេចក្ដីវិនាសទៅពេលក្រោយអំពីពួកអស់អ្នកទាំងនោះមិនខាន ព្រោះអ្នកចាញ់តែងចងពៀរនឹងអ្នកឈ្នះជាដ៏រាប ។

នៅទីបំផុតនៃគំនិតនេះ អ្នកបានក្រាបថ្វាយបង្គំលាព្រះមហាក្សត្រត្រឡប់ទៅផ្ទះវិញ ។

ក្នុងខណៈដែលកុមារជ័យរៀបនឹងត្រឡប់មកផ្ទះវិញនោះ ពួកអស់អ្នកបានក្រាបបង្គំទូលព្រះមហាក្សត្រថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំមានសេចក្ដីក្ដៅក្រហាយនឹងអាជ័យខ្លាំងណាស់ បើព្រះអង្គមិនស្វែងរកទោសឲ្យទូលព្រះបង្គំទាំងអស់គ្នានេះទេ សេចក្ដីក្ដៅក្រហាយមិនរសាយចេញពីខ្លួនទូលព្រះបង្គំឡើយ ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា រឿងនេះបានអញកាត់ឲ្យស្មើរនោះប្រសើណាស់ទៅហើយ បើនាងទាំងឡាយ នៅតែមិនអស់សេចក្ដីក្ដៅក្រហាយទៀត នោះមានតែឲ្យអញប្រើឯងឲ្យនាំគ្នាទៅចុះអាចម៍ដាក់ផ្ទះវាតាមអំពើចិត្តឯងតែម្ដងទៅ ទើបបានស្កប់ចិត្តឯងរាល់គ្នាឬអី ។ ចំណែកខាងអញ ៗ មិនដឹងជារករឿងដូចម្ដេច នឹងធ្វើ

ទោសដល់មនុស្សគ្មានកំហុសបានឡើយ ព្រោះជាហេតុនាំឲ្យខូចសេចក្ដីយុត្តិធម៌របស់អញផង នាំឲ្យខូចកិត្តិយសរបស់មហាក្សត្រផង ។ អញនឹងប្រតិបត្តិតាមកំដៅចិត្តឯងពលរដ្ឋគ្មានបានទេ ព្រោះហេតុអញជាមហាក្សត្រគ្រប់គ្រងប្រទេស មិនមែនជាមហាក្សត្រគ្រប់គ្រងតែនាងឯងពលរដ្ឋប៉ុណ្ណោះនាក់ទេ ចូរដឹងឲ្យច្បាស់ក្នុងចិត្តយ៉ាងនេះតទៅ ។

កុមារជ័យដើរចេញមកសទន្សមៗ បានស្ដាប់ព្រះរាជឱង្ការទាំងនេះហើយត្រឡប់ទៅផ្ទះវិញទៅ ។

ពួកអស់អ្នកទាំងនោះនឹកអាក់អន់ស្រពន់ពេក ដោយព្រះមហាក្សត្រមិនសម្រេចសេចក្ដីតាមបំណងរបស់ខ្លួន ។

លុះកន្លងទៅបានចំនួនជា ៤-៥-ថ្ងៃ មានអស់អ្នកម្នាក់បានបំផុះព្រះរាជបន្ទូលអំពីថ្ងៃមុន ហើយនាំគ្នាពិចារណាថា កាលពីប៉ុន្មានថ្ងៃមុននោះ ដូចជាឮព្រះរាជបន្ទូលថាឲ្យយើងទៅដុះអាចម៍ដាក់ផ្ទះអាជ័យ ឬយ៉ាងណា ? ។

ដោយហេតុតែសេចក្ដីក្ដៅក្រហាយមានខ្លាំងខ្លានៅក្នុងខ្លួនជាប់ជានិច្ច នាំឲ្យអ្នកខ្លះដែលស្ដាប់មិនច្បាស់យល់ថា ប្រាកដជាព្រះករុណាជាម្ចាស់លើត្បូងប្រើឲ្យទៅដុះអាចម៍ដាក់ផ្ទះកុមារជ័យ, នាំឲ្យអ្នកដែលស្ដាប់ច្បាស់ទាំងនោះបណ្ដោយគំនិតស្រេចទៅតាមនោះ ព្រោះអាងថា បើខ្លួននាំគ្នាទៅដុះដាក់ទៅព្រះមហាក្សត្រមិនយកទោសដែរ មួយទៀតព្រោះអាងថា ខ្លួនមានគ្នាច្រើន នឹងពោលបន្ទំព្រះរាជបន្ទូលនោះបាន ។

ពួកអស់អ្នកទាំងនោះ ក៏បញ្ចេញយោបល់ស្របគ្នាថាត្រូវតែនាំគ្នាទៅដុះអាចម៍ដាក់ផ្ទះកុមារជ័យ តាមព្រះរាជបន្ទូល ។

ថ្ងៃនោះដួនជាឯក នឹងនាងកាណា ជាឪពុកម្ដាយកុមារជ័យចេញទៅប្រកបការ

ឯកាល នៅតែកុមារជ័យម្នាក់ឯង ។

មិនយូរប៉ុន្មានស្រាប់តែពួកអស់អ្នកបាននាំគ្នាឡើងស្រវមកលើផ្ទះខ្ទះ នៅដីខ្ទះ នាំគ្នាជុះអាចម៍ដាក់ផ្ទះខ្ទះ ជុះអាចម៍ដាក់ដីភូមិខ្ទះ ។

កុមារជ័យលុះឃើញដូច្នោះ ក៏ពិចារណាក្នុងចិត្តថាឃើ ! អើ ! ថ្ងៃនេះ ហេតុអ្វីក៏ប្លែកអស្ចារ្យម្ល៉េះ អំពើនេះកើតឡើងដោយចិត្តឯង ឬ កើតឡើងដោយព្រះរាជហឫទ័យនៃព្រះមហាក្សត្រ បើកើតឡើងដោយចិត្តឯងក៏ឃើញថាមិនសម ។ បើកើតឡើងដោយព្រះរាជបញ្ជា ក៏ឃើញថាមិនសម ដូច្នេះត្រូវតែអញវាយពួកអស់អ្នកទាំងនេះកំចាត់ចេញកុំឲ្យជុះអាចម៍ប្រឡាក់ផ្ទះអញច្រើនពេក បើមានរឿងដូចម្ដេចសឹមអញដោះសារទៅតាមនោះ ។

លុះពិចារណាឃើញដូច្នេះហើយ ស្ទុះទៅយករំពាត់មកវាយអស់អ្នកទាំងឡាយ ។ ក៏រត់ខ្ចាត់ខ្ចាយប្រូតះប្រតាក់ចេញទៅទាំងកំពុងដោះទុកសត្វតូច-ធំនោះ ។

ពួកអស់អ្នកទាំងនោះមានសេចក្ដីក្ដៅក្រហាយជាខ្លាំង ក៏នាំសេចក្ដីនោះទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរនោះសព្វគ្រប់ ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយ យកព្រះហស្ដឹតព្រះឬកដកដង្ហើមយូរៗ ថាឃើ ! អើ ! អំពើមិនគប្បីនេះ នាំឲ្យរវល់ទៀតហើយតើ ។ ម្ដងនេះត្រូវអញគិតដូចម្ដេច បើអញយកខ្លួនទៅពាំងពួកអស់អ្នកទាំងនេះ នាំឲ្យខ្មាស់អាជ័យ បើអញមិនយកខ្លួនទៅពាំងទេ មុខតែអស់អ្នកទាំងនេះត្រូវមានទោស បើដូច្នេះត្រូវអញលៃលករឿងនេះឲ្យបានសម្រេចទៅដោយបទណា ដើម្បីឲ្យគូវិវាទទាំងសងខាងបានសុខចិត្តផង លុះទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទ្រង់យល់ឃើញភ្លាមថា រឿងនេះត្រូវវិនិច្ឆ័យ

តាមការពិត ប៉ុន្តែត្រូវឲ្យគ្រូវីវាទចូលមកកាន់សំណាក់អញម្ខាងម្តង ហើយនិយាយដោយផ្ទាល់សម្ងាត់ទើបបាន ។

ក្រោយដែលព្រះអង្គទ្រង់តម្រិះឃើញដូច្នេះ ទ្រង់មានព្រះតម្រាស់ឲ្យទៅចាប់កុមារជ័យយកមក អាមាត្យក៏ទទួលបាត់តាមព្រះតម្រាស់នោះ លុះទៅដល់ផ្ទះកុមារជ័យ ហើយនាំគ្នាស្ទុះទៅបម្រុងនឹងចាប់កុមារជ័យ ។ ស្រដីមកកាន់អាមាត្យទាំងនោះវិញថា នែ ! លោកទាំងឡាយ ការដែលលោកមកបម្រុងនឹងចាប់ចងខ្ញុំនេះ លោកបានគិតទុកជាមុនឬទេ ?

អាមាត្យ នែ ! អាជ័យ គិតពីរឿងអី ? ។

កុមារជ័យ-គិតពីព្រះរាជបន្ទូល ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ត្រាស់ប្រើមកនេះ នឹងគិតពីកិច្ចសន្យាដែលអស់លោកព្រមចាញ់ខ្ញុំទេ នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រតាំងពីថ្ងៃមុនមកនោះ ។

អាមាត្យ– អាឯងឲ្យអញគិតយ៉ាងម៉េច? បើដល់ពេលត្រូវចាប់អាឯងហើយ ។

កុមារជ័យ– ឲ្យអស់លោកគិតថា ទ្រង់ត្រាស់ប្រើមកឲ្យគ្រាន់តែហៅ ឬឲ្យចាប់, ឲ្យគ្រាន់តែចាប់, ឬឲ្យចងផង, បើឲ្យចង តើចងយ៉ាងណា ? ចងនឹងចំណងអ្វី បើចាប់ចងរួចហើយ ឲ្យនាំខ្ញុំទៅដោយអ្វី? ។ មួយឲ្យអស់លោកគិតថា កាលពីថ្ងៃមុនអស់លោកសុខចិត្តចាញ់ខ្ញុំ ឥឡូវម៉េចក៏មកចង់ឈ្នះខ្ញុំវិញ ។

អាមាត្យ– ម៉េចក៏អាឯងចាំសួរអញយ៉ាងនេះ ឯងដឹងទេ អញជានាយតម្រួតនៃព្រះមហាក្សត្រប្រើមកហើយ ស្រេចតែនឹងចិត្តអញ ។

កុមារជ័យ–បើវាស្រេចតែចិត្តលោក តើលោកអាចសម្លាប់ខ្ញុំមុនព្រះមហាក្សត្រគាត់

ទោសបានឬទេ? លោកអាចប្រព្រឹត្តរំលងពាក្យសន្យានៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្របានឬទេ?

អាមាត្យ– អញសម្លាប់ឯង ដូចជាពាក្យអាឯងសួរនេះមិនបានទេ, អញប្រព្រឹត្តរំលងកិច្ចសន្យាចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រមិនបានទេ,

កុមារជ័យ– ព្រោះហេតុអ្វី? ក៏សម្លាប់មិនបាន ប្រព្រឹត្តរំលងមិនបាន បើវាស្រេចតែចិត្តលោកទៅហើយ ។

អាមាត្យ– ព្រោះការសម្រេចទោសនៅលើព្រះមហាក្សត្រ ការដែលដល់នៅលើអញ ការប្រព្រឹត្តរំលងកិច្ចសន្យាជាកំហុសមួយធំ ។

កុមារជ័យ– បើព្រះមហាក្សត្រទ្រង់សម្លាប់ អស់លោកអាចយកទៅកាត់កសម្លាប់បានឬទេ? ពាក្យសន្យាដែលលោកពោលចំពោះព្រះមហាក្សត្រយ៉ាងនេះ តើលោកត្រឡប់ជាធ្វើយ៉ាងនោះទៅវិញបានឬទេ? ។

អាមាត្យ– ធ្វើដូច្នេះមិនបានទេ ។

កុមារជ័យ– ហេតុអ្វី បានជាធ្វើយ៉ាងនេះមិនបាន ។

អាមាត្យ– ព្រោះខុសនឹងព្រះរាជបញ្ជា ព្រមទាំងល្មើសនឹងខសន្យារបស់ខ្លួន ។

កុមារជ័យ– អុញហ៎! ត្រង់ខនេះនិយាយថាខ្លាចខុសនឹងព្រះរាជបញ្ជា ខុសនឹងខសន្យា ចុះត្រង់មកចាប់ចងខ្ញុំ ហេតុអ្វីក៏មិនខ្លាចខុសនឹងព្រះរាជបញ្ជា ឬខុសនឹងខសន្យាផង ។ ហៃ៎! ត្រង់នេះ ហើយដែលខ្ញុំសួរថា អស់លោកបានគិតទុកជាមុនហើយ ឬនៅ? បានជាខ្ញុំសួរបញ្ឆក់យ៉ាងនេះ ខ្ញុំដឹងថា អស់លោកមកនេះប្រញាប់ប្រញាល់ណាស់ ស្ដាប់ព្រះរាជបន្ទូលមិនច្បាស់លាស់ផង ប្រកបដោយទោសចិត្តភ្លេចគិតដល់ខសន្យាផង ។

(នៅមានត)

## សាសនាជេន និងពុទ្ធសាសនា (តពីទំព័រ១១)

## អភិនេស្ក្រមន៍ នៃមហាវីរៈ

កាលដែលមហាវីរៈ មានអាយុ២៨ឆ្នាំមាតាបិតាក៏ទិវង្គតអស់ហើយ ៗ មហាវីរៈ ចង់ចេញសាងតបៈនៅពេលនោះភ្លាម ៗ, ប៉ុន្តែបងប្រុសជាទីស្រឡាញ់ពោលពាក្យតួញត្អែរជាខ្លាំងថា "ឱប្អូនសម្លាញ់, មាតាបិតាយើងទើបនឹងទិវង្គតទៅថ្មី ៗ, សេចក្ដីទុក្ខក្រៀមក្រម សោកសៅខ្សឹកខ្សួលបង្អៀតអង្អល់ កំពុងបិតនៅគ្របសង្កត់លើវង្ស ត្រកូលធ្ងន់ក្រៃពេក, បានប្អូនជាអ្នកមានបញ្ញាឈ្លាសវៃគ្រាន់បរបារំដោះទុក្ខសោក, បើប្អូនចេញចាកត្រកូលបាត់ទៅទៀតនោះ សេចក្ដីទុក្ខសោកនឹងរឹតតែចំរើនឡើងទ្វេគុណ" ៗ មហាវីរៈ បានស្ដាប់ពាក្យបងក៏ស៊ូអត់ទ្រាំនៅបានពីរឆ្នាំទៀត ៗ

លុះដល់អាយុ៣០ឆ្នាំ, បរិយាកាសក្នុងសង្គមកាន់តែអាប់អួរខ្លាំងឡើង ៗ ប្រាកដដល់ចិត្តមហាវីរៈ, មហាវីរៈទ្រាំនៅតទៅទៀតពុំបាន ក៏ចេញចាកគេហស្ថាននៅពេលព្រលប់ថ្ងៃ១៥រោចខែមិគសិរ ឆ្លងកាត់កុណ្ឌបុរី ទៅដល់ឧទ្យានឈ្មោះសណ្ឌវ័ន ជារបស់ញាតិកខត្តិយត្រកូល ចូលទៅកាន់ដើមអសោកមួយដើមធំ ហើយតាំងខ្លួនជាអ្នកបួសក្នុងទីនោះ ៗ

គម្ពីរជេនឈ្មោះកល្បសូត្រ គេបានពណ៌នាជាអនេកប្បរិយាយ អំពីរឿងមហាវីរៈចេញបព្វជ្ជា ថាពេលនោះមានទេវតាតាមហែហមមហាវីរៈ តាំងពីមាត់ទ្វារនៃនិវេសន៍ដ្ឋានទៅ ដូចជាគម្ពីរពុទ្ធសាសនាយើងដែលពណ៌នាអំពីការចេញសាងអភិនេស្ក្រមន៍នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង ដែលមានទេវតាហែហមទ្រជើងសេះជាដើមដូច្នោះដែរ ៗ គម្ពីរដដែលនេះ មានពណ៌នាថា ពេលចូលទៅដល់ក្រោមដើមអសោក

ហើយ មហាវីរៈអង្គុយតែនក្នុងដោះគ្រឿងអលង្ការចោលចេញទាំងអស់, យកដៃខ្លួនឯងចាប់បោចសក់ពេញមួយក្តាប់ ៗ តែ៥ក្តាប់ ក៏អស់រលីងពីក្បាលហើយអង្គុយអត់អាហារអត់ទាំងទឹក អស់ពីរថ្ងៃទើបស្លៀកដណ្តប់សំពត់ដែលទេវតានាំយកមកឲ្យ ។

## ញាណ ៥ យ៉ាងរបស់មហាវីរៈ

គម្ពីរកល្បសូត្រពណ៌នាថា មហាវីរៈបានសម្រេចញាណ៥ប្រការ ។ បណ្តាញាណទាំង៥ប្រការនោះ មហាវីរៈបានសម្រេចញាណ ៣ ខាងដើមតាំងពីកំណើត គឺ:—

១— មតិ ការយល់ហេតុការណ៍ផ្សេងៗដែលកើតចំពោះមុខ, ។

២— ស្រុតៈ ឬ ពហុស្សូត ការបានស្តាប់ច្រើនដឹងច្រើន, ។

៣— អវធិ ការអាចកំណត់ព្រំដែននៃហេតុការណ៍ផ្សេង ៗ,

ពេលមុនចេញសាងតបៈបានសម្រេចញាណទី៤គឺ: —

៤— មនៈបយ៌ាយៈ ការស្ទាបស្ទង់ទឹកចិត្តអ្នកដទៃ,

ពេលបួសហើយខំប្រឹងបំពេញទុក្ករកិរិយា គឺអត្តកិលមថានុយោគអស់ ១២ ឆ្នាំ បានសម្រេចញាណទី៥គឺ:—

៥— កេវលកប្បៈ ញាណដែលអាចដឹងបានពុំមានសេសសល់ ។ (ជេនិកសាវ័កយល់ថាញាណនេះប្រៀបបាននឹងសព្វញ្ញុតញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធ, ព្រោះហេតុនោះ ជួនកាលគេហៅញាណនេះថាសព្វញ្ញុតញ្ញាណ) ។

## ទុក្ករកិរិយា

លុះបួសរួចហើយ, ដោយដឹងថាវង្សត្រកូលរបស់ខ្លួនធ្លាប់ជាសាវ័កនៃលទ្ធិបាស៌្វនាថ (តិត្ថំករទី២៣) តៗគ្នាមកហើយ, មហាវីរៈក៏ចូលទៅនៅអាស្រ័យប្រតិបត្តិធម៌ក្នុង

ក្រុមអ្នកបួសនៃលទ្ធិបាស៌្វនាថនោះ ។ តែមហាវីរៈប្រព្រឹត្តតឹងរឹងប្លែកពីគេ ពុំមានអ្នកណាធ្វើតាមបាន ពោះបើលទ្ធិនោះពុំបានបង្គាប់ឲ្យធ្វើដូច្នោះក៏ដោយ ។ ពេលនោះមហាវីរៈលះបង់សំលៀកបំពាក់ចោលចេញ ដើរអាក្រាតខ្លួនទទេ ពុំមានវត្ថុបន្តិចបន្តួចជាប់នឹងខ្លួនសោះ សូម្បីបាត្រ ឬ ភាជន៍សំរាប់ដាក់អាហារក៏ពុំមាន, ចូលទៅកាន់ភូមិកាលបើគេយកអាហារភោជនមកឲ្យ ក៏ក្បង់ដៃទទួលយកមកបរិភោគ, លែងអើពើដល់សេចក្តីសុខទុក្ខរបស់រាងកាយសោះ មុស សុជ បុចខាំកន្ទួលកន្ទុះ រគាំងរគេម ពេញទាំងខ្លួន ធ្វើឲ្យរាងកាយទ្រុតទ្រោមស្គមកំព្រឹងទៅជាឈើ, ប៉ុន្តែ មហាវីរៈបានកំចាត់បង់ពុំគិតដល់ការឈឺចាប់នៃរាងកាយ ដោយការអត់ធ្មត់ដែលហៅថាខន្តី ។ ប្រជាជនបានឃើញមហាវីរៈប្រព្រឹត្តដូច្នោះ, ខ្លះស្លុតចិត្ត, ខ្លះថាមហាវីរៈឆ្កួត, ខ្លះយករំពាត់ ឬដំបងវាយវាត់ ខ្លះទៀតយកដុំដី ដុំឥដ្ឋ ឬ ដុំថ្ម ចោលលើសរីរៈមហាវីរៈ ។ នោះបើគេធ្វើបាបដល់ខ្លួនដូច្នោះ ឬ មានគេសួរអំពីរឿងដែលប្រព្រឹត្តបែបនោះ មហាវីរៈវៀរស្រឡះពុំព្រមឆ្លើយសោះប្រឹងតែធ្វើតបៈធម៌ ទាំងថ្ងៃទាំងយប់ឥតឈប់ឈរ ។ រដូវវស្សាចូលទៅអង្គុយសង្ងំស្ងាត់ខ្លួនទទេក្នុងទីម្លប់ត្រជាក់, រដូវក្តៅចេញទៅអង្គុយធ្វើតបៈហាលថ្ងៃ, ប្រព្រឹត្តអត់អាហារ អត់ទឹកជាដើម ។ ប្រមាណជាងពីរឆ្នាំខាងក្រោយបំផុត មហាវីរៈឈប់ប្រើទឹកត្រជាក់សោះ ប្រើតែទឹកក្តៅ ពីរបីថ្ងៃម្តង ។ រួបរួមទាំងអស់ប្រមាណ១២ឆ្នាំ មហាវីរៈ ក៏បានឃើញច្បាស់ យល់ច្បាស់ នូវបថវីកាយ អាបោកាយ តេជោកាយ វាយោកាយជាដើម បន្សាត់បង់អំពើបាបគ្រប់យ៉ាងដោយផ្លូវកាយវាចាចិត្ត បានសម្រេចញាណឈ្មោះកេវលកប្បៈ នៅថ្ងៃ១០កើតខែពិសាខ ក្នុងអាយុកាល៤២ឆ្នាំ ។

# ការប្រកាសសាសនា

តពីនោះ មហាវីរៈ ក៏ចាប់ផ្ដើមត្រាច់រង្គាត់គ្រប់ទិសទីទេសនាផ្សាយលទ្ធិរបស់ខ្លួន ដូចជាព្រះពុទ្ធជាម្ចាស់ដែរ ។ ដំបូងបានជួបគោសាល នៅនាលន្ទា ។ គោសាលឃើញសមត្ថភាពនិងការប្រព្រឹត្តរបស់មហាវីរៈ ក៏ជ្រះថ្លាយ៉មខ្លួនធ្វើជាសាវ័កមហាវីរៈ ។ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន ពុំដឹងជាដោយហេតុអ្វី គោសាលបានបែកចិត្តអំពីមហាវីរៈ ទៅតាំងនិកាយមួយផ្សេងហៅថាអាជីវកនិកាយ ។ គោសាលនេះក៏គឺ មក្ខលិគោសាល ដែលតែងឃើញ ពោលដល់ក្នុងគម្ពីរពុទ្ធសាសនា ។

សម័យមួយមហាវីរៈ មានឱកាសល្អទាក់យកសាវ័កបានជាច្រើន ។ ពេលនោះ មហាវីរៈដឹងថា សោមិណាចារ្យព្រាហ្មណ៍កំពុងធ្វើពិធីមហាយញ្ញ នៅកន្លែងមួយមិនឆ្ងាយប៉ុន្មានពីជម្ភិកគ្រាម ក៏ទៅកាន់ទីបូជានោះដែលមានប្រជាជនកកកុញបានប្រកាសលទ្ធិរបស់ខ្លួនក្នុងចំណោមព្រាហ្មណ៍បរិស័ទនោះ ។ មហាវីរៈ បានសំដែងអំពី ជីវៈ អជីវៈ អាសវៈ ពន្ធៈ សំវរៈ និរជរ មោក្ខ (និព្វាន) ។ លុះចប់ហើយព្រាហ្មណ៍ជាប្រធាន១១នាក់ដែលមានព្រាហ្មណ៍ឈ្មោះគោត្តមឥន្ទ្រភូតិ ជាដើមជាងគេ បានជឿបួសតាមមហាវីរៈ ព្រមទាំងបរិស័ទរបស់ខ្លួន ៗ ចំនួនជាង៤.០០០ (បួនពាន់) រូប ។ ពួកព្រាហ្មណ៍ទាំង១១នាក់នេះគេហៅ ឯកាទសវគ្គិយគណធារៈ ។ តាំងពីនោះមកគេហៅមហាវីរៈថា សព្វញ្ញូ ។

តមកទៀតមហាវីរៈ តែងត្រាច់រង្គាត់កៀរគរបរិស័ទខាងណេះខ្លះ ខាងណោះខ្លះ បានកើនច្រើនឡើងជាលំដាប់ ។

(នៅមានត)

# រចនាវិលាសពាក្យភាសាអង់គ្លេស (តចប់)

Common mistake (កំហុសស្រាលៗ)

1- Don't say : He considers AS his best friend.

say : He consider me his best friend.

(គាត់សំគាល់ (យល់ឃើញ) ថាខ្ញុំជាមិត្តឆ្នើមរបស់គាត់)

Don't say : He regards me his best friend.

say : He regards me AS his best friend.

(បានសេចក្ដីដូចគ្នានឹងប្រយោគលើ)

Note : កាលប្រើពាក្យ «consider», កុំប្រើ «as» ជាមួយផង

. " " «regard» ត្រូវប្រើ «as» " "

2- Wrong use (ការប្រើខុស) of «the» with «man» densting (ដែលសំដៅសេចក្ដីដល់) human race (មនុស្សជាតិ)

Don't say : The man is born a sinner.

say : Man is born a sinner.

(មនុស្សកើតហើយ តែងជាអ្នកប្រព្រឹត្តបាប)

សេចក្ដីថាមនុស្សជាតិគ្រប់រូប កាលបើពុំទាន់បានសម្រេចមគ្គផល, និព្វានទៅឡើយ តែងមានសន្ដានប្រកបដោយកិលេស ដែលជាគ្រឿងដឹកនាំឲ្យប្រព្រឹត្តអំពើអាក្រក់មានប្រការផ្សេងៗ ប្លែកគ្នា ខ្លះមានកិលេសច្រើន ខ្លះតិចប៉ុណ្ណោះ ៗ អ្នកដែលមានកិលេសតិចទន់ខ្សោយ ពុំសូវប្រព្រឹត្តធ្វើបាបនោះយើងក៏នាំគ្នាសន្មត់ថាជាមនុស្ស

ល្អ; ប៉ុន្តែតាមពិតអ្នកទាំងអស់នោះក៏ឈ្មោះថាបិតនៅក្នុងកំលេស (ក្នុងបាប) ដូចៗគ្នា ៗ ព្រោះហេតុនោះ ទើបមាន ភាសិតថា «Man is born a sinner»

Note : ស័ព្ទដែលប្រើសាធារណៈទូទៅដូចពាក្យ «man» ក្នុងប្រយោគនេះមិនត្រូវប្រើ កាវន្ត (article) «the» ទេ.

ប្រើ «the» បានតែក្នុងប្រយោគដែលសំដៅសេចក្តីដល់មនុស្សដែលធ្លាប់ស្គាល់ ឬដែលបាននិយាយដល់ ក្នុងខាងដើមហើយ ក្នុងរឿងជាមួយគ្នា ៗ

3- «Before yesterday» etc. used instead of «The day before yesterday» (ថ្ងៃម្សិលម៉្ងៃ) etc. It is wrong!

Don't say : We arrived before yesterday.

say : We arrived the day before yesterday.

(យើងមកដល់ពីថ្ងៃម្សិលម៉្ងៃ)

The phrases «before yesterday», «after tomorrow», «after next week» are incorrect. Say instead of these (ប្តូរពោលជំនួសពាក្យទាំងនេះ) «The day bafore yesterday (ថ្ងៃម្សិលម៉្ងៃ)», « the day after tomorrow (ថ្ងៃខានស្អែក)», «the week after next week· (អាទិត្យបន្ទាប់អាទិត្យក្រោយ)».

---

JOKE

A small boy, pointing to a very fat and stout man on weighing

រឿងកំប្លែង

កុមារតូចមួយរូប, ចង្អុលទៅតបុរសម្នាក់ធាត់ដុះពោះ (ដែលឈរ) លើជញ្ជីង

machine that is OUT OF ORDER and is recording only one kilogram, said: « I say, Bill, this man must be hollow! »

យន្តដែលខូច ហើយដែលប្រាប់ទម្ងន់បានតែត្រឹមមួយគីឡូក្រាមប៉ុណ្ណោះ, និយាយថា: «អៃយ៉ា», ប៊ីល, តួនេះច្បាស់ជាមានប្រហោងក្នុង!» ។

IDIOM: Out of order = (out of stock; damaged)

ខូច (គ្រឿងម៉ាស៊ីន); រហែករហុយ (សៀវភៅ); បាក់បែក (វត្ថុផ្សេងៗ);

1- Your watch is OUT OF ORDER

នាឡិកាលោកខូចហើយ

2- Wy grammar book is OUT Of stock. I can't LEND it to you please, BORROW it from other.

សៀវភៅវេយ្យាករណ៍ខ្ញុំរហែករហុយអស់ហើយ ខ្ញុំពុំអាចឲ្យលោកខ្ចីបានទេ សូមខ្ចីពីអ្នកដទៃទៀតចុះ ។

Notice the use of «lend» and «borrow» !

ចូរសង្កេតពីរបៀបប្រើពាក្យ "lend" (ឲ្យខ្ចី) នឹង "borrow" (ខ្ចី) ។

3- This cock is damaged. Please, do not use it!

ក្បាលម៉ាស៊ីនទឹកនេះខូច (បាក់បែក) ហើយ, សូមមេត្តាកុំប្រើវា!

Here ends the second lesson

មេរៀនទី ២ ចប់តែត្រឹមប៉ុណ្ណោះ

LOOK FORWARD TO your third lesson in the COMING VOLUME!

សូមរង់ចាំអានមេរៀនទី៣ របស់លោកក្នុងភាគតទៅ (ភាគបន្ទាប់នេះ)

មហាវិបណ្ឌិតោ (អាំ-សួន ហៅ ហម)

វិជ្ជាស្ថាននាលន្ទា (ឥណ្ឌា)

រោងពុម្ពទវិយ
នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ ៥